ឈាង ហាប់ អាន

# ប្រជុំអនុពាក្យ

សំរាប់
ថ្នាក់ទី៣ ទំនើប
និង ការប្រឡងមធ្យមសិក្សា

បណ្ណាគារ ត្រៃរតន៍

B-7
D-482.1
N° 161/
ក.52

482.1

ឡាង ហាប់អាន

# ប្រជុំអនុពាក្យ

សំរាប់

## សញ្ញាប័ត្រមធ្យមសិក្សា

ការផ្សាយរបស់

បណ្ណាគារ ត្រៃរតន៍

លេខ ៣៥ វិថីឧកញ៉ា ទេព-ផន ភ្នំពេញ

(អ្នកនិពន្ធរក្សាសិទ្ធិគ្រប់យ៉ាង)

បោះពុម្ពលើកទី ១

ព.ស. ២៥១២ គ.ស. ១៩៦៩

# អារម្ភកថា

—०0०—

ហេតុដែលបណ្ដាលឲ្យកើតសៀវភៅ **ប្រជុំអនុពាក្យ** សំរាប់ **សញ្ញាប័ត្រមធ្យមសិក្សា**(១) នេះឡើងគឺដោយសារលោក ជាង គង់ ទ្រី ម្ចាស់បណ្ណាគារត្រៃរតន៍ លេខ ៣៥ វិថី ឧកញ៉ា ទេព-ផន បានមកអង្វរខ្ញុំឲ្យធ្វើជាញឹកញយពេក រកប្រកែកបង្ករកួតពុំរួច ។ ដំបូង ខ្ញុំមិនប្រាថ្នាធ្វើសៀវភៅនេះទេ ពីព្រោះអស់លោកអ្នកនិពន្ធ មិត្តភក្ដិ ព្រមទាំងសាស្ត្រាចារ្យជាច្រើនបានធ្វើយូរមកហើយ ជាច្រើនគ្នា រាប់ដល់ប្អូនក៏សឹងបាន ហើយខ្ញុំមានចិត្តធ្ងើងកន្ទ្រើនថា សៀវភៅបែបនេះងាយធ្វើ ងាយចម្លងគ្នាពីមួយទៅមួយ ដោយសារថាយើងគ្រាន់តែស្រង់អត្ថបទអំពីស្នាដៃរបស់គេឯងដែលល្អ ៗ រួចចងជាសំនួរ ហើយតាំងតែពីបើកវចនានុក្រម បើកវេយ្យាករណ៍ រាប់សន្លឹកចម្លង កាឡៃបន្តិចត្រង់នេះ បន្តិចត្រង់នោះ ចម្រុះគ្នាដូចសម្ល

(១) នេះម្ចាស់បណ្ណាគារទេ ដែលសុំឲ្យឈ្មោះដូច្នេះ ។

កគួរ ក៏អាចចងក្រងស្អាតដាក់សង្ហារបង្អួតពាន គាប់ឫក បញ្ចោញនាមបព្រាង បំភ័ន្តភ្នែកសិស្សានុសិស្ស សាស្ត្រាចារ្យ ដែលចាល់គុំចម្ពង ៗ ឬមានការសន្នអន់ក្រ ខ្វះឯកសាររៀន បង្រៀន ទិញឡប់អាចម៍ទៀ ចំណេញឯម្ចាស់បណ្ណាគារ បានលុយដាក់ខ្ទៃណេនផ្ទះ ។

បើនិយាយពីអត្ថបទផ្នែកប្រឡងហើយវិញ ខ្ញុំដែលជាអ្នកសន្សំសៀវភៅ ឬ ឯកសារម្នាក់នោះ មានគ្រប់បែបយ៉ាង ប៉ុន្តែចែកជូនមិត្តភក្តិខ្លះ ៗ ឲ្យយកទៅរៀបរៀងមុន (ឧទាហរណ៍វិញ្ញាសាប្រឡងសញ្ញាប័ត្រមធ្យមសិក្សា) តាំងពីឆ្នាំ ១៩៥៦ មកដល់បច្ចុប្បន្ននេះ ។ ប៉ុន្តែសិយសារ៉ កើតឆេះផ្ទះ និងក្បួនអស់មួង នៅឆ្នាំ ១៩៦០ ក៏សល់នៅតែក្បួន ឯកសារសន្សំក្រោយ ៗ ពីឆ្នាំ ១៩៦០ នោះមក ។ ក្នុងសៀវភៅនេះ ខ្ញុំផ្ដល់ជ្រុលដៃថាធ្វើនោះ ខ្ញុំនឹងរៀបចំឲ្យបានច្រើនភាគទៅទៀត សំរាប់ជួយដល់ការខ្វះខាតអត្ថបទសំរាំងខ្លី ៗ ហើយមានខ្លឹមសារក្នុងការបង្រៀន ការរៀន ការប្រឡងប្រជែងនានា ៗ

ក្នុងភាគទីមួយនេះ ខ្ញុំបញ្ចូលវិញ្ញាសាប្រឡងមធ្យមសិក្សាប័ត្រ ព្រមទាំងការប្រឡងប្រជែងសំខាន់ៗ នៃវិជ្ជាជីវៈខ្លះជាច្រើន ជាងអត្ថបទសំរាំងថ្មីៗ របស់អ្នកនិពន្ធថ្មីៗ ឬចាស់ ឬអត្ថបទផ្ទាល់ខ្លួន ។

ក្នុងការចេញសៀវភៅ ប្រជុំអនុពាក្យនេះ ខ្ញុំមានការអៀនខ្មាស់ច្រើន ព្រោះហាក់ដូចជាខ្លះរឿងសរសេរនេះម៉្យាង ហើយម៉្យាងទៀតហាក់ដូចជាឬកឯងជំនាញការគ្រប់ជំពូក ធ្វើអ្វីក៏កើតទាំងអស់ ។ ការពិត បានជានិយាយបែបនេះ ពីព្រោះភាគច្រើននៃសៀវភៅនេះ ត្រូវពឹងផ្អែកជំនួយនានាមាន វចនានុក្រម វេយ្យាករណ៍ពល់ប្អូន ដែលជូនកាលមើលរបស់គេហើយ ធ្វើមាយាឯង ជារៀបចំឃ្លាសំដីឲ្យប្លែក យកខ្លួនដើម្បីកុំឲ្យគេថាឬចោទថាចម្លងគេត្រង់ៗពេក ។ ប៉ុន្តែទោះយ៉ាង

ណាក៏អស់លោកមិត្តភក្តិ មិនសើច មិនយំ ឬរិះគន់ខ្ញុំប៉ុន្មានទេ
ពីព្រោះខ្ញុំធ្វើតម្រូវចិត្តលោកថៅកែ ជាមិត្តជិតស្និទ្ធម្នាក់ដែរ
របស់ខ្ញុំ ដែលខ្ញុំអស់តំរេះនឹងគេប ឬ ករលោកទៀតលែងរួច
តែប៉ុណ្ណោះ ។

ភ្នំពេញ ថ្ងៃទី ២៩ កញ្ញា ២៥០៩ / ១៩៦៦

**ឈាង ហាប់ អាន**

សាស្ត្រាចារ្យខាងវិជ្ជាខ្មែរ

# សរសេរតាមសូត្រ

## ១– ផ្ដើមសេចក្ដី

ពាក្យ " **សរសេរតាមសូត្រ** " ជាសព្ទដែលយើងប្រើមកជាយូរយាហើយ សម្រាប់សំគាល់ន័យរបស់ពាក្យបារាំងថា "Dictée" ឬ " Orthographe " នោះឯង ។ ឥឡូវនេះ អស់លោកអ្នកប្រាជ្ញ អ្នកនិពន្ធខ្លះ ប្រែ ហើយប្រើពាក្យផ្សេងៗ គ្នាសំរាប់សំគាល់សព្ទ " **សរសេរតាមសូត្រ** " " Dictée ឬ Orthographe " នេះជា

– **សរសេរតាមអាន**

– **អនុពាក្យ**

– **សរសេរតាមហៅ**

ជាដើម ដោយសំអាងទៅតាមបំណូលចិត្ត ទិដ្ឋិមានះ ឬ តាមការយល់ឃើញផ្ទាល់រៀងៗខ្លួន ( ខ្លះអាចថា ហៅ

**សរសេរតាមសូត្រ** មិនត្រូវទេ ព្រោះគេមាន "**សូត្រ**" ឯណា; ត្រូវថា "**សរសេរតាមអាន**" វិញ ព្រោះគេអានឲ្យយើង**សរសេរ** តាម ៗ ខ្លះថាត្រូវហៅ **សរសេរតាមហៅ** វិញ ព្រោះគេ **ហៅ** ពាក្យ ឃ្លាប្រយោគឲ្យយើង **សរសេរ** ៗ ហើយខ្លះទៀតប្រែថា "**អនុពាក្យ**" ឲ្យប្លែកតែម្ដងទៅទៀត ៗ

ចំពោះខ្លួនខ្ញុំ ខ្ញុំយល់ថាអស់លោកអ្នកនិយមប្លែក ៗ គាប់បែបនេះមិនទាស់ទេ (ព្រោះនរណាយល់ ចូលចិត្តយ៉ាងណា ទុកយ៉ាងនោះចុះ ពីព្រោះយើងគ្មានបណ្ឌិតសភា = Académie ដើម្បីវិនិច្ឆ័យ បង្កើតពាក្យឲ្យមានឯកភាពនៅឡើយ) ហើយដែលសំខាន់គឺឋិតនៅត្រង់គោលបំណង ន័យសេចក្ដីរបស់ពាក្យឯណោះទេ ដែលមានប្រយោជន៍ ពោលគឺឲ្យតែយល់គោលបំណង ប្រើទៅបានផល ធ្វើឲ្យគេស្ដាប់សេចក្ដីនិងគំនិតគោលបំណងរបស់យើងបានស្រប ៗ ខ្ញុំពុំមែនជាមនុស្សរក្សានិយមទេ ប៉ុន្តែ ដោយពាក្យ Dictée ឬ Orthographe

នេះ យើងធ្លាប់ប្រើមកស្គាល់គ្រប់ៗ គ្នាហើយ គប្បីគោរពគុណឲ្យនៅថា " **សរសេរតាមសូត្រ** " សិនចុះ ។

## ២_ គោលបំណងនៃការសរសេរតាមសូត្រ

តាមគោលបំណងចង្អៀតចង្អល់ ឬ គោលបំណងខ្លី " **សរសេរតាមសូត្រ** " បង្ហាត់បង្រៀនសិស្សឲ្យចេះសរសេរពាក្យពេចន៍ = les mots ឬ ស័ព្ទ = les termes ក្នុងអត្ថបទណាមួយឲ្យបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធនៃពាក្យ = l'orthographe du mot ឬ ត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ប៉ុណ្ណោះ = règle grammaticale ។ ប៉ុន្តែគោលបំណងខ្លីបែបនេះពុំទាន់គ្រប់គ្រាន់ទេ ពីព្រោះសរសេរតាមសូត្រ "មិនមែនតម្រូវឲ្យសរសេរពាក្យ = les mots ឬ សរសេរស័ព្ទ = les termes តែឯកឯង មួយ ឬ ពីរ ដប់ ឬ ម្ភៃ ឯណា គឺគេយកអត្ថបទទាំងមូល (ខ្លីល្មម ឬ វែងបង្គួរអំពីក្នុងរឿង ក្នុងស្នាដៃអ្នកនិពន្ធណាមួយ) មកហៅអានឲ្យសិស្សសរសេរឡើងវិញ គឺក្នុងគំនិតដូចតទៅ ៖

ទី ១- ឲ្យសិស្សរំលឹកនឹកឃើញ ចេះសរសេរពាក្យ ពេចន៍ ស័ព្ទ ឃ្លាប្រយោគ សេចក្ដីដែលខ្លួនធ្លាប់ឃើញ ធ្លាប់អាន ធ្លាប់រៀនត្រង់នេះខ្លះ ត្រង់នោះខ្លះ ក្នុងមេរៀនដទៃទៀត ឲ្យបានត្រឹមត្រូវឡើងវិញ ;

ទី ២- ឲ្យសិស្សរំលឹកនឹកឃើញ ព្រមជាមួយគ្នានឹងការចេះចាំសរសេរពាក្យពេចន៍ ឃ្លាប្រយោគនោះៗ ហើយយល់ស្គាល់ នូវលំអនៃអត្ថបទដែលជាស្នាដៃរបស់អ្នកនិពន្ធណាមួយ ដោយកាន់តែយល់ ដឹងថាអត្ថបទនោះៗ ថា មានសម្រស់ អានតម្លៃក្នុងការតែង ក្នុងគោលគំនិតអប់រំ ទូន្មានតម្រែតម្រង់ "បែបណាមួយ"ៗ

គឺគោលគំនិតទី ២ នេះហើយ ដែល "សរសេរតាមសូត្រ" ហាក់ដូចជាមានន័យសេចក្ដី និងមានគោលបំណងទូលំទូលាយ ហើយមានប្រយោជន៍មិនតិចតួចទេ ចំពោះ

សិស្សានុសិស្ស យុវជន (ពិសេសក្នុងមធ្យមសិក្សាបឋមភូមិ និងបឋមសិក្សា) ។

ដូច្នេះ សរសេរតាមសូត្រ ក្នុងគោលបំណងទី ២ នេះ ទាក់ទងទៅនឹងចំណោះចេះដឹងដូចតទៅ ៖

ទី ១– ការស្គាល់ ចេះចាំច្បាស់លាស់ នូវពាក្យពេចន៍ សព្ទពិបាក ៗ ឬ ងាយស្រួល (ដែលយើងឲ្យឈ្មោះថា ចេះអក្ខរាវិរុទ្ធ = orthographe du mot),

ទី ២ – ការស្គាល់ យល់ច្បាស់ នូវន័យនិយម = la définition, le sens នៃពាក្យពេចន៍ ឬ សព្ទដែលប្រើធម្មតា ប្រើក្នុងអត្ថបទ (ហេតុដូច្នេះ ទើបគេតម្រូវឲ្យសិស្ស ពន្យល់ពាក្យពិបាក ៗ ឬ ពាក្យថ្មី ៗ ខ្លះ ក្នុងសរសេរតាមសូត្រ នៅពេលក្រោយកិច្ចការនេះ គឺហៅថាការពន្យល់ពាក្យ = “ Explication des mots ” នេះឯង ។ ចំណោះចេះដឹងក្រោយនេះ ទាក់ទងនៅនឹង ៖

— ពាក្យសព្ទ = Vocabulaire (គឺការស្គាល់និងយល់ន័យរបស់ពាក្យនីមួយៗ);

— ការប្រើពាក្យ ដោយយកទៅប្រើក្នុងឃ្លា ក្នុងប្រយោគ ហៅ Construction des phrases;

— ការស្គាល់ឫសគល់ កំណើត សន្តានរបស់ពាក្យ (១) (ធាតុ = racine; បុព្វបទ = préface; បច្ឆិមបទ = suffixe; សន្តានពាក្យ = famille des mots; សទិសសព្ទ = homonyme; វេវចនសព្ទ = synonyme; ពាក្យផ្ទុយ = contraire ជាដើម(២)) ។

---

១) នៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ សាស្ត្រាចារ្យកេង វ៉ាន់សាក់ បានប្រើពាក្យសំរាប់ប្រែសព្ទទាំងឡាយនេះ ឲ្យមានឯកភាពល្អណាស់ ក្នុងការបង្រៀនវេយ្យាករណ៍ និងនិរុត្តិវិទ្យាខ្មែរ ។

២) ពាក្យទាំងឡាយនេះមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រប្រែថា : ធាតុ racine, បុព្វសព្ទ = préfixe, បច្ឆិមសព្ទ = suffixe សព្ទញាតិ = famille des mots; សព្ទជាតិ = nature des mots; សព្ទរូប = synonyme; សព្ទសូរ = homonyme; សព្ទន័យ = sens des mots; បដិសព្ទ = contraire des mots.

ទី ៣– ការរំលឹកនឹកឃើញ ស្គាល់ និងចាំច្បាស់ ហើយ

ចេះអនុវត្តប្រើនូវមេរៀនវេយ្យាករណ៍ ក្នុងការតែ

ឧទាហរណ៍ រំលឹកមេរៀនត្រង់កន្លែងណាមួយ, ធ្វើ

សម្ពន្ធពាក្យ, សម្ពន្ធឃ្លា ឬ ប្រយោគជាដើម ដែលគេ

ចោទសួរ នៅក្នុងសំនួរ ។

ទី ៤– យល់គំនិត ឬ គោលបញ្ហាសំខាន់ៗ នៃអត្ថបទ

ដែលគេចោទសួរក្នុងសំនួរ ។

គឺលក្ខណៈទាំង ៤ ខធំៗ ខាងក្រោយនេះហើយ ដែល "សរសេរតាមសូត្រ" ទៅជាការសិក្សាដ៏ចាំបាច់ ហើយ មានប្រយោជន៍សំខាន់ចំពោះសិស្សានុសិស្ស នៅបឋមសិក្សា មធ្យមសិក្សាបឋមភូមិ មុននឹងឡើងទៅដល់មធ្យមសិក្សា មធ្យមភូមិ ព្រមទាំងឧត្តមសិក្សា ដែលគេតម្រូវឲ្យរៀនអំពី ការតែងសេចក្ដី និងការពិភាក្សា អត្ថាធិប្បាយអត្ថបទ (គឺអត្ថ-បទវិជ្ជា) ដែលជាការសិក្សាមានកម្រិតវិជ្ជាខ្ពស់ជាងនេះ ។

## ៣- ប្រភេទនៃសរសេរតាមសូត្រ[១]

តាមប្រភេទវិភាគវិធីសាស្ត្រ នៃការបង្រៀន (របស់គ្រូ និងសាស្ត្រាចារ្យ) សរសេរតាមសូត្រមាន ២ យ៉ាងគឺ:

ទី ១_ សរសេរតាមសូត្ររៀបចំ = La Dictée préparée ដែលមានលក្ខណៈ អនុវត្តិសឹងតែប្រហែលគ្នានឹងការពន្យល់អត្ថបទ ( អត្ថបទវិជ្ជា = explication du texte ) យ៉ាងនោះ ។ ប្លែកជាង ត្រង់គេពន្យល់អំពីអក្ខរាវិរុទ្ធនៃពាក្យ ព្រមទាំងការពន្យល់អំពីទ្រឹស្តី ក្បួនវេយ្យាករណ៍ច្រើនជាងប៉ុណ្ណោះ ។

កាលណាធ្វើសរសេរតាមសូត្ររៀបចំនេះរួច លុះដល់ថ្ងៃក្រោយ ( ពេលម៉ោងបង្រៀនវិជ្ជានេះនៅពេលក្រោយ ) ទើបគេយកអត្ថបទដដែលនោះ មកហៅឲ្យសិស្សសរសេរតា-

---

(១) ខ្ញុំមិនបានអធិប្បាយពង្រីកសេចក្តីឲ្យទូលំទូលាយ អំពីប្រភេទ = (Catégorie) នៃសរសេរតាមសូត្រនីមួយ ៗ នេះទេ ហើយឯវិធិផ្សេងៗ សំរាប់ប្រភេទនីមួយ ៗ នេះទៀតក៏ខ្ញុំមិនអធិប្បាយឲ្យវាតទំព័រវែងសេចក្តីឡើយ។

និត្យរំលឹកឡើងវិញ ដែលគេឲ្យឈ្មោះថា ៖

ទី២- សរសេរតាមសូត្រត្រួតពិនិត្យ = La dictée de contrôle

សរសេរតាមសូត្រនេះតម្រូវឲ្យសិស្សធ្វើក្នុងសៀវភៅកិច្ចការ ដោយគ្រូឬសាស្ត្រាចារ្យដាក់សំនួរឲ្យធ្វើថែម ហើយប្រមូលយកទៅកែដើម្បីពិនិត្យថាតើសិស្សចេះចាំពាក្យពេចន៍ យល់ន័យមេរៀនទាំងនា ដែលពន្យល់ហើយក្នុងការរៀបចំលើកមុន ព្រមទាំងចាំមេរៀនវេយ្យាករណ៍ដែលបានរៀនរួចឬទេ?

គឺសរសេរតាមសូត្រទាំងពីរបែបនេះហើយដែលគេអនុវត្តិបង្រៀនសិស្ស តាំងពីថ្នាក់បឋមសិក្សាមកទល់ថ្នាក់ទី៣ ទំនើប នៃមធ្យមសិក្សាបឋមភូមិប្រឡងមធ្យមសិក្សាប័ត្រ = Diplôme d'Etudes Secondaires du 1er cycle នោះឯងៗ

៤- វិធីជ្រើសរើសអត្ថបទសរសេរតាមសូត្រ .-

ជារៀងៗ គ្រូនិងសាស្ត្រាចារ្យ ឬអ្នករើសវិញ្ញាសា

សំរាប់ឲ្យសិស្ស ឲ្យបេក្ខជនអនុវត្តិ ច្រើនយល់ច្រឡំថា “ការរើសអត្ថបទសរសេរតាមសូត្រ” ត្រូវរកអត្ថបទណាដែលមានពាក្យថ្មី ៗ ពិបាក ៗ ច្រើន ។ គេពុំចាំបាច់គិតដល់ខ្លឹមសារនៃអត្ថបទនោះឡើយ ។

ការយល់បែបខាងលើនេះ ខុសស្រឡះ ។ បើយល់បែបនេះ គឺមិនចាំបាច់យកអត្ថបទតាំងមូល ទៅឲ្យសិស្សសរសេរឬប្រឡងទេ គប្បីរើសតែពាក្យថ្មី ៗ ពិបាក ២០ ទៅ ៣០ ឬ ៥០ ម្តងយកទៅហៅឲ្យសិស្សសរសេរ ប្រឡងជាការស្រេច ហើយគេមានពេលច្រើនចាំតែចាប់កំហុសវាងាយផង ។

ការពិត បើយោលទៅលើគោលបំណង (ក្នុងផ្នែកទី២) ខាងលើ “ការរើសអត្ថបទសរសេរតាមសូត្រ” ទៅដាក់ឲ្យសិស្ស ឬបេក្ខជនធ្វើជា **ការក្រ ពិបាក** ដូចគ្នានឹងជ្រើសរើសអត្ថបទសំរាប់យកទៅពន្យល់ អត្ថាធិប្បាយក្នុងអត្ថបទវិជ្ជា: explication du texte យ៉ាងនោះដែរ ។ យ៉ាងណាមិញ គេត្រូវ:

ទី ១– រើសអត្ថបទដែលមានពាក្យពេចន៍ពិបាកល្មម (កុំ

ចិត្តខំតែងអត្ថបទមានសុទ្ធតែពាក្យថ្មីៗ បាលីបាគូ ដែលគ្រូ ឬសាស្ត្រាចារ្យ ឬអ្នកតែងខ្លួនឯងមិនយល់ មិនដឹងន័យ ហើយប្រើខុសថែមទៀត)[1]។

ទី ២– រើសអត្ថបទដែលមានខ្លឹមសារ[2] ទាក់ទងនឹងការអប់រំ ការដៅចិត្តគំនិតយុវជន សិស្សទៅរកលក្ខណៈជាតិនិយម ប្រយោជន៍និយម ដែលបិតនៅលើគំនិតស្មារតីខ្ពង់ខ្ពស់ ប្រាសចាកភាពអពមង្គល ធ្វើឲ្យស៊ុញ តុះតុញចិត្តក្លាហាន អង់អាច និងភាពល្អបរិសុទ្ធ ស្អាតស្អំ ស្រឡាញ់ការងារជា

---

(១) ខ្ញុំតែងឃើញអ្នកនិពន្ធ ឬ សាស្ត្រាចារ្យ មេប្រយោគជាច្រើន ៗ រើសអត្ថបទបែបនេះ ទៅបង្ក្រងជាសៀវភៅ ជាក្បួន ឬយកទៅឲ្យសិស្សប្រឡង ។ លុះដល់ពេលកែម្ដង ៗ ជជែកគ្នាបែកពពុះមាត់តែពីសរសេរខុស ឬត្រូវ ឡើងក្ដៅស្លឹកត្រចៀក ។

(២) គឺអត្ថបទទី ២នេះហើយ ដែលគ្រូ សាស្ត្រាចារ្យ ឬ អ្នកនិពន្ធត្រូវរិតខំស្រាវជ្រាវ ដកស្រង់ កែតម្រូវឲ្យយុវជនសិក្សាអនុវត្តនោះ ។

ដើម ៗ អត្ថបទបែបនេះ បើតែខ្លួន
ឯងមិនបានទេ គេអាចដកស្រង់ពីស្នាដៃ
អ្នកនិពន្ធសំខាន់ៗ អ្នកជាតិនិយម, កូន
សុន្ទរកថា សង្កថារបស់ឥស្សរៈ ឬវរៈជន
ជាតិ (មានអត្ថបទសម្តេចព្រះប្រមុខរដ្ឋ កូន
សារពត៌មាន ទស្សនាវដ្តីនានាជាដើម) ៗ

ទី៣ – រើសអត្ថបទឲ្យខ្លីល្មម តែមានលក្ខណៈ
ច្បាស់លាស់ គឺកុំឲ្យវែងដល់ទៅពីរបីទំព័រ
(សូមលៃយ៉ាងណាត្រឹមមួយទំព័រ ឬមួយ
ទំព័រកន្លះ ដែលមានរយៈពេលទាំងហោច
ទាំងសិស្សសរសេរចប់ ត្រឹមសែសិបប្រាំ
នាទី) ប៉ុណ្ណោះ ៗ

## ៥– វិធីជ្រើសរើសសំនួរនិងការឆ្លើយសំនួរ.–

### ក) ការជ្រើសរើសសំនួរ.–

តាមធម្មតា សំនួរមានជាបែបផ្សេងៗ ដូចជា :

ទី១— ការពន្យល់ពាក្យ = Explication des mots ឬសំនួនពាក្យ ( សំនួនវោហារ ) = Expressions ។

ការជ្រើសរើសពាក្យ កុំសំដៅតែលើពាក្យពិបាកៗ ឬថ្មីៗ (មានបាលី សំស្ក្រឹតពេក) ។ គឺសួរឲ្យល្មមសិស្ស បេក្ខ-ជនគ្នាយល់ គ្នាពន្យល់បានផង ។ តែសួរពិបាកពេក នាំឲ្យសិស្សលួចស្ដាយយកវចនានុក្រមទៅលបបើកមើល ហើយខិតខំតែពន្យល់តាមសៀវភៅគំរូ ភ្លេចន័យមែនទែនក្នុងសេចក្ដីនៃអត្ថបទអស់រលីង ។

ក្នុងសំនួរនេះ សួរមេពាក្យយ៉ាងច្រើន ត្រឹម ៥ ពាក្យ ជាការគួរ ។

ទី២— ការសួរអំពីមេរៀនវេយ្យាករណ៍ :

គេអាចសួរពី :

១— ការរំលឹកពីមេរៀនណាមួយក្នុងវេយ្យាករណ៍ (ដូចជាសួរពីន័យនិយមរបស់នាម គុណនាម កិរិយាស័ព្ទ វចនៈ លិង្គ វណ្ណយុត្តិណាមួយ ឬអំពីវិធីប្រើពាក្យនោះៗ) ;

២– ការសួរឲ្យរកឧទាហរណ៍ បញ្ជាក់លើមេរៀនណាមួយក្នុងវេយ្យាករណ៍ ( ដូចជាឲ្យរកសាធារណនាមសំគាល់ មនុស្ស សត្វ រុក្ខជាតិ វត្ថុនានា, អសាធារណនាម, វិសេសគុណនាម, អតិវិសេសគុណនាម, សកម្មកិរិយា, អសកម្មកិរិយា, សព្វនាម ។ល។ ) – ឲ្យរកឧទាហរណ៍ក្នុងអត្ថបទមកបញ្ជាក់ត្រឹម ៥ ពាក្យយ៉ាងច្រើន ។

៣– ការសួរឲ្យធ្វើសម្ពន្ធផ្សេងៗ គឺ:

ក)– សម្ពន្ធពាក្យ = Analyse grammaticale (កុំឲ្យហួស ៥ ពាក្យ ) – គឺសួរពាក្យត្រង់នេះមួយ ត្រង់នោះនោះមួយក៏បាន ឬ សួរឲ្យធ្វើសម្ពន្ធពាក្យម្តងមួយៗ ក្នុង ១ ឃ្លាល្មមត្រឹម ប្រាំ ឬ ៦ ពាក្យក៏បាន ;

ខ)– សម្ពន្ធឃ្លាប្រយោគ = Analyse logique ( ដោយយើងពុំទាន់មានឯកភាពក្នុងការប្រើ ឬ ធ្វើវេយ្យាករណ៍ខ្មែរនៅឡើយនេះម្យ៉ាង ហើយម្យ៉ាងទៀត យើងពុំអាចធ្វើវេយ្យាករណ៍យើងដែលជាខ្មែរឲ្យ ឆាកទៅរកបាលី សំ-

ស្ក្រឹត ឬ បារាំង ដែលគេមានឃ្លាប្រយោគប្លែកពីខ្មែរ គេមានវិភត្តិ = Conjugaison និងការចងឃ្លាផ្ទុយពីយើងនោះ តាមយោបល់ខ្ញុំ ខ្ញុំថាកុំអាលបង្ខំសួរពីសម្ពន្ធឃ្លាប្រយោគនេះ ទុកចាំថ្ងៃក្រោយ សាស្ត្រាចារ្យ វេយ្យាករណ៍របស់យើងមូលមាត់និយាយ តែងត្រូវគ្នាសិន សឹមអនុវត្តប្រើ) ។

ទី ៣ – ការសួរគោលគំនិតសំខាន់ៗ :

ក) ក្នុងអត្ថបទ ដោយ :

– ឲ្យបែកអត្ថបទជាផ្នែក ហើយដាក់ឈ្មោះចំណងជើងតូចៗ នៃផ្នែក ;

– ឬមួយសួរពីគោលបំណង (គឺឧត្តមគតិ, យោបល់រួម ឬ មូលបញ្ហា គឺបញ្ហាជាខ្លឹម ជាគោល) នៃអត្ថបទក៏បាន ។

– ឬ សួរពីលក្ខណៈ (គុណសម្បត្តិ ឬ គុណវិបត្តិ) នៃតួអង្គក្នុងអត្ថបទ ។

– ឬមួយ បើអត្ថបទគ្មានចំណងជើង អាចសួរឲ្យរក

បំណងដើម នៃអត្ថបទ ។

១) ក្នុងសតិបញ្ញា :

ស្ទង់ចំណេះវិជ្ជារបស់សិស្ស ឬ បេក្ខជន ដោយសួរទាក់ទងទៅនឹងចរិយាវិជ្ជា សីលវិជ្ជា ស្មារតី ជាតិនិយម បញ្ហាចំរើនប្រទេស (ដូចជាសួរពីគំនិតកសាងជាតិ គោរពច្បាប់ គោរពវិន័យ មានសីលធម៌ល្អ ជាដើម) ។

## ២)- ការឆ្លើយសំនួរ.-

ចំពោះសំនួរ គេច្រើនសួរម្តង ៣ (ក្នុងចំណោមសំនួរទាំងឡាយខាងលើ) (ក្នុងផ្នែកទី ៥ ក) ។

សិស្ស ឬ បេក្ខជន មិនចាំបាច់គោរពតាមលំដាប់សំនួរទេ ពោលគឺមិនចាំបាច់ធ្វើពីសំនួរទី ១ ហូរហែទៅទី ២ និងទី ៣ រៀងគ្នាយ៉ាងនេះឡើយ ។ បើយល់ថាសំនួរទី ១ពិបាក ទី ២ ស្រួលជាងនោះ គេធ្វើទី ២ មុន ឬ ទី ៣ ដែលស្រួលទៅទៀតមុន រួចសឹមធ្វើទី ១ ឬ ធ្វើណាមួយដែលងាយ បាន

តាមចិត្ត តែត្រូវបង់លេខបញ្ជាក់រៀងសំនួរឲ្យច្បាស់ ដើម្បីមេប្រយោគងាយកែ ឆាប់ឃើញថា យើងធ្វើសំនួរណាមុន និងណាក្រោយ ៗ

## ៦_ ការប្រុងប្រយ័ត្នក្នុងការសរសេរ._

ធម្មតា ក្នុងវិធីសរសេរតាមសូត្រ គ្រូ សាស្ត្រាចារ្យ ឬ មេប្រយោគ ហៅ ៣ ដង (គឺក្រោយមើលឲ្យយើងស្តាប់មួយចប់ជាដំបូង) ៗ ឯហៅបីដងនោះ គឺ:

— លើកទី ១ ហៅឲ្យសរសេរ (គេអាចហៅម្តងមួយឃ្លា ឬ ពាក់កណ្តាលឃ្លា ត្រឹមបួនប្រាំម៉ាត់ឡើងទៅ)

— លើកទី ២ ហៅឃ្លាដដែលសារឡើងវិញ

— លើកទី ៣ ហៅឃ្លាដដែលជាបញ្ចប់ ដើម្បីស្រួតទៅហៅឃ្លាតទៅទៀត ៗ

នៅពេលចប់អត្ថបទ គេមើលអត្ថបទនោះសន្សឹម ៗ ឡើងវិញ ៗ

ដូច្នេះ បើសរុបការហៅ ឬ ការអានទៅ មានដល់ទៅ ៥ដង ៗ ក្នុង៥ដងនេះ ល្មមឲ្យសិស្ស បេក្ខជនស្ដាប់ទាន់ ប្រុងប្រយ័ត្ន គិតឡើងវិញ រំលឹកទឹកឃើញល្អណាស់ ៗ ប្រសិនបើយើងមានស្មារតីមូល ប្រុងប្រយ័ត្ន គឺគ្មានភ័យថា សរសេរមិនទាន់ ឬរំលងឡើយ ៗ តែក្នុងករណីផ្ទុយទៅវិញ (គឺថាស្ដាប់មិនទាន់ ឬ សរសេររំលង) នោះ គេត្រូវប្រុងប្រយ័ត្នសំរាប់លើកទី ១ ឬ ទី ៤ បានគ្រប់គ្រាន់ណាស់ៗ ក្នុងពេលកំពុងសរសេរ បើសង្ស័យពាក្យណាសរសេរខុស គេសរសេរសិនទៅ ហើយយកខ្មៅដៃគូសចំណាំពីក្រោមពាក្យនោះបន្តិច ដើម្បីសរសេរចប់ សឹមពិចារណាឲ្យត្រឹមត្រូវ ៗ ក្នុងពេលសរសេរ មិនត្រូវខិតខំពិចារណាឲ្យខាតពេល រហូតដល់ភ្លាំងភ្លាត់ស្មារតីលែងស្ដាប់ គ្រូ សាស្ត្រាចារ្យ ឬ មេប្រយោគហៅនោះឲ្យសោះ ៗ

ក្នុងករណីខ្លះ គេមិនហៅ **ដកឃ្លា** ឡើយ ៗ ដូច្នេះ យើងត្រូវទៅប្រុងស្ដាប់នៅពេលហៅសារឡើងវិញ នៅលើក

បញ្ចប់ទី ៥ ឯណោះ (ប៉ុន្តែ តាមរបៀបខ្មែរយើង ករណីនេះ មិនសូវមានទេ) ។

### ៣– យោបល់រួម.–

សរុបសេចក្ដីទៅ យើងឃើញថា សរសេរតាមសូត្រ ពិតជាមេរៀនមានប្រយោជន៍ មិនតូចទាបជាងការសិក្សាឯ-ទៀត ៗ មានអត្ថបទវិជ្ជា គណិតវិជ្ជា មេសូត្រក្នុងវិជ្ជានានា ឬតែងសេចក្ដីឡើយ ។ ក្នុងការប្រឡងប្រជែងនានា សរសេរតាមសូត្រជួយពិន្ទុឲ្យងាយស្ដារពិន្ទុឯទៀត ៗ ផង ព្រមទាំងជួយទាញពិន្ទុឯទៀតឲ្យធ្លាក់ថយចុះដោយសារវាផងក៏មាន ។ បានសេចក្ដីថា បើសរសេរតាមសូត្រខុស ៥ ឬខុស ១០ ពាក្យ នឹងមុខជាបានសូន្យ ។ ប៉ុន្តែ បើខុស ៥ ពាក្យហើយ កុំអាលអស់សង្ឃឹម ព្រោះនៅសល់ពិន្ទុពាក់កណ្ដាលទៀត (បើ ២០ ពិន្ទុ គេបែកសរសេរតាមសូត្រ ១០ ពិន្ទុ និងសំនួរ ១០ ពិន្ទុ) សំរាប់សំនួរដែរ ។ ដូច្នេះ គេត្រូវខិតខំធ្វើសំនួរឲ្យត្រូវបានល្អ ដើម្បីស្ដារពិន្ទុកុំឲ្យសូន្យឈឹងលិចស្រឹម ដល់គ្មានបាន

មួយគ្រាប់សោះ (ពីព្រោះសូន្យក្នុងមុខវិជ្ជាណាមួយ នោះការប្រឡងនឹងត្រូវបដិសេធ = Zéro éliminatoire) ។ ប្រសិនបើបេក្ខជនធ្វើសរសេរតាមសូត្រតតខុសសោះ ឬ ខុសបន្តិចបន្តួច ហើយធ្វើសំនួរបានល្អ នោះពិន្ទុនឹងបានថ្លោស ហើយជាគន្លឹះនៃលទ្ធផល ក៏នឹងសំរេចយ៉ាងញញឹមស្រស់ ។

ឯកំហុស និងគម្លៃកំហុសផ្សេងៗ ក្នុងសរសេរតាមសូត្រ គឺមានដូចតទៅនេះ ៖

ទី ១– សរសេរខុសពាក្យ គឺ :

– ខុសពីអ្នកគេអាន (ដូចគេអានថា **សម្បត្តិ** សរសេរជា **សំបាច់**) = គេបាប់ខុស ១ ពេញ

– ខុសដោយស្តាប់មិនបាន សរសេរប្រថុយ (ឧ. **យល់** សរសេរជា **ជល់**) = គេពាប់ខុស ១ ពេញ

ទី ២– សរសេរខុសអក្ខរាវិរុទ្ធ ដោយពាក្យនោះពិបាក ឬ ពាក្យថ្មី មានបាលី សំស្ក្រឹតលាយ

(ឧ. **វិញ្ញាណ** ជា **វិញ្ញាណ** ឬ **វិញ្ញាន**=

គេចាប់ខុសកន្លះបាន

ទី ៣– សរសេរខ្វះសក់, ជើង, វណ្ណយុត្តិ ស្រៈ

ដែលនាំឲ្យខុសន័យ (ឧ. = **កាច់** ជា

**កាច** ; **សីល** ជា **សើល** ; **ជ័យ** ជា **ជយ**;

**ឆ្ងាញ់** ជា **ឆ្ញាញ់** = គេចាប់ខុស ១ ពេញ

ទី ៤– សរសេររំលងឬខ្វះមួយពាក្យ = –”– ១ ពេញ

ទី ៥– សរសេរលើស ១ ពាក្យ = –”– ១ ពេញ

ទី ៦– សរសេរខុសវេយ្យាករណ៍(១) = –”– ១ ពេញ

---

(១) ដើម្បីសិក្សាបន្ថែមនូវចំណេះចេះដឹងនេះ សូមសិស្សអានខ្លួនឯងទៀត នូវ :

– វចនានុក្រមខ្មែរ ភាគ ១–២ (របស់ពុទ្ធសាសនបណ្ឌិត្យ);

(ត្ងង)

— វចនប្រទីប (របស់ សហ. សុង-ស៊ីវ ; — វិធីប្រើវណ្ណយុត្តិ (របស់ សហ. នួន-ប៊ុត ); — សរសេរតាមសូត្រឱប្ចម (របស់ សហ. ជឹម-ពៅ ); — នវវេយ្យាករណ៍ និងខេមរភាសា (របស់ សហ. សៀន-ខ័នឌី និងព្រហ្មវីរៈ); — វេយ្យាករណ៍ខ្មែរ (ពូវ-អ៊ុម ); — អក្ខរាវិរុទ្ធតាមវេយ្យា-ករណ៍ (គិម-សែត ); — វិធីបង់បទសម្ពន្ធ (គិម-សែត ); — នវវេយ្យាករណ៍ (ព្រហ្មវីរៈ ) ; — សម្ពន្ធខ្មែរ (គិម-សែត ); — សម្ពន្ធវេយ្យាករណ៍ និង សម្ពន្ធមាលា (ព្រហ្ម-វីរៈ ); — មូលភាពនៃការបង្កើតពាក្យថ្មី (កេង-វ៉ាន់សាក់ ); — វេយ្យាករណ៍ និង ភាសាខ្មែរ (គិម-សែត ); — ខេមរវេយ្យាករណ៍សង្ខេប (ល. ហ. អ. ); — ក្បួនសរសេរខាងសទិសស័ព្ទ (ជឹម-ពៅ ); — អក្ខរានុក្រម វេវចនស័ព្ទខ្មែរ (ឌិក-គាម ); — វេយ្យាករណ៍ខ្មែរ (ញ៉ឹក-នូវ ); — បេះខ្មែរ (ហ៊ែល-ស៊ុំផា ); — វេយ្យាករណ៍ខ្មែរសង្ខេបភាគ ១ (កេង-វ៉ាន់សាក់ ); — វិធីអានអក្សរ ភាសាខ្មែរ (ឈឹម-ស៊ុម) និងអនុពាក្យសំពាំង (ទីវ-អុល ) ។

## ទី១– អំពីព្រះមហាក្សត្រិយ៍(១)

ព្រះមហាក្សត្រិយ៍ ដែលទ្រង់គ្រប់គ្រងប្រទេសនីមួយៗ(២) ព្រះអង្គជាទេពាដោយសន្មត(៣) ទ្រង់ព្រះនាមថា " ព្រះរាជា " ព្រោះទ្រង់ប្រកបដោយការសង្គ្រោះប្រជាជនដោយសង្គហវត្ថុបួនយ៉ាង គឺប្រទានទេយ្យវត្ថុ មានព្រះវាចាគួរឲ្យចង់ពុ ចង់ស្តាប់ ទ្រង់ប្រព្រឹត្ត(៤) អំពើជាប្រយោជន៍ ទ្រង់តាំងព្រះអង្គស្មើៗ គឺប្រើបុគ្គលឲ្យ(៥) ល្មមពេញចិត្តប្រជាជនៗ

(១) ក្នុងវចនានុក្រមខ្មែរភាគ១ ទំព័រ ៨១៤ គេអាចសរសេរ មហាក្សត្រ ដូច្នេះ ក៏បានដែរ ។

(២) គេច្រើនប្រទ្បូសរសេរ នីមួយ ៗ (មើល វ. ន. ខ. ភាគ១ ទំព័រ ៤៩១ ) ។

(៣) គេសរសេរបាន ២យ៉ាង គឺ *សន្មត* ឬ *សម្មត* (វ. ន. ខ. ភាគ២ ទំព័រ ១២៣៨ ) ។

(៤) គេច្រើនច្រឡំសរសេរ *ប្រព្រិត្ត* ឬ *ប្រព្រឹត្តិ* ដែលជានាម (វ. ន. ខ. ភាគ១ ទំព័រ ៦៤០ ) ។

(ធ្លង)

ទ្រង់តម្រង់ប្រជាជនដោយទសពិធរាជធម៌ ។ ធម្មៈសំរាប់ព្រះរាជាមានដប់យ៉ាងគឺ អំណោយទាន រក្សាសីលប្រាំជានិច្ច អំណោយព្រះរាជទ្រព្យ ទំនុកបំរុង(១)ប្រទេស មានសេចក្ដីទៀងត្រង់ ទន់ភ្លន់ សុភាព រក្សាឧបោសថសីលតាមកាលកំណត់មួយ ១ មិនកំដៅក្រហាយប្រជាជន មិនបៀតបៀនអ្នកដទៃ(២) មានសេចក្ដីអត់ធន់មិនបំពានលើធម៌ លើច្បាប់ ។

ដោយហេតុនេះ ទើបមានព្រះនាមថា បុត្តការីរបស់ប្រជាជន(៣) ។

សម្ដេចព្រះមហាសុមេធាធិបតី **ជួន.ណាត**

វិញ្ញាសាប្រឡងរើសសិស្សគរុកោសល្យ គ..ស ១៩៥៦

---

(៥) គេមិនអាចសរសេរ ទុយ ឬ ទិយ ឬ គាយ (តាម មហាវិទ្យាល័យអក្សរសាស្ត្រ) ដូច្នេះទេ ។ វចនានុក្រមភាគ ២ ទំព័រ ១៨៤៦ ជាសរសេរបែបនេះពុំបានជាប់ខាត ។

(១) គេអាចសរសេរ បំរុង ឬ បម្រុង បាន (វ. ន. ១. ភាគ ១ ទំព័រ ៥៦៨) ។

(ជួន)

## សំណួរ

១– ចូរពន្យល់ពាក្យ : ទសពិធរាជធម៌, សីល, បុព្វការីរបស់ប្រជាជន ។

២– ហេតុអ្វីបានជាព្រះរាជនិពន្ធ ទ្រង់មានព្រះបន្ទូលថា ព្រះមហាក្សត្រ ជាទេវតាដោយសន្មត ?

៣– សទិសស័ព្ទនឹងពាក្យ : ពារ

៤– ចូរបញ្ជាក់ពីវិធីប្រើវណ្ណយុត្តិ រធាន ។

## ចម្លើយ

១– ការពន្យល់ពាក្យ .–

**ទសពិធរាជធម៌**(១) = រាជធម៌ ១០ យ៉ាង គឺធម៌ ១០ ប្រការសម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីធំតូចនិងពួករាស្ត្រប្រជាឲ្យប្រព្រឹត្តផង ។

ទសពិធរាជធម៌នោះគឺ :

---

(១) ជានាម (បាលី = ទសវិធ+រាជធម្ម) វ.ន.វ. ភាគ១ ទំព័រ ៣៩៦

(២) កុំច្រឡំនឹង ដ៏ ជានិបាតសព្ទ បានន័យថា ដែល, ដែលជា ( ខ.

(ឆ្លង)

១– **ទានៈ** = ការឲ្យទាន ;

២– **សីលៈ** = ការរក្សាសីល ៥ ជានិច្ច ឬរក្សា សីល ១០ មួយដងមួយកាល ;

៣– **បរិច្ចាគៈ** = ការបំណាយព្រះរាជទ្រព្យទំនុកបំរុងព្រះនគរ ;

៤– **អាជ្ជវៈ** = មានសេចក្ដីត្រង់ ;

៥– **មទ្ទវៈ** = មានសេចក្ដីទន់ក្លន់ស្លូត សុភាពរាបសា ;

៦– **តបៈ** = ការកាន់ឧបោសថសីល តាមកាលកំណត់មួយៗ ;

៧– **អក្កោធៈ** = មិនកំដៅក្រហាយអ្នកដទៃ ;

៨– **អវិហឹសា** – មិនបៀតបៀនអ្នកដទៃ ;

៩– **ខន្តិ** = មានសេចក្ដីអត់ធន់ ;

១០– **អវិរោធនៈ** = មិនបំពានលើធម៌ លើច្បាប់ៗ

---

ធម្មិធិបរិ (វ. ន. ១. ភាគ១ ទំព័រ ២៩០) ។

(៣) អត្ថបទនេះ មានចុះក្នុង ៥០ សរសេរតាមសូត្រ របស់មិត្ត លិមលាង-ជិន ក្នុងឆ្នាំ ១៩៦១ ម្ដងហើយ ។

ច្រើនហៅកាត់ខ្លីត្រឹមតែ ទសពិធ ឬទសពិធធម៌(១) ។

**សីល**(២)= ការវៀរចាកអំពើអាក្រក់; ការកាន់ឬប្រព្រឹត្តល្អដោយកាយ វាចា; ការមិនប្រព្រឹត្តកន្លងសិក្ខាបទ ឬវិន័យបញ្ញត្តិ; ការកាន់ចរិយាល្អ; ការសង្រួម; សេចក្ដីល្អ;

**បុព្វការីរបស់ប្រជាជន** = ជនជាអ្នករក្សាទំនុកបម្រុងប្រជាជន (ក្នុងអត្ថបទ គឺសំដៅព្រះមហាក្សត្រដែលទុកដូចជាជនដើម ជនអ្នកធ្វើឧបការគុណមុន គឺអ្នកដែលបានធ្វើសេចក្ដីទំនុកបម្រុងផ្ទុំផ្ដើមប្រជាជនរួចមកហើយ) ។

២– ព្រះរាជនិពន្ធមានព្រះបន្ទូលថា ព្រះមហាក្សត្រជាទេព្ដាដោយសម្មត ព្រោះព្រះអង្គជាបុព្វការី ពោលគឺអ្នករក្សាទំនុកបម្រុងផ្ទុំផ្ដើមសង្គ្រោះប្រជាជន ឲ្យបានប្រកបទៅដោយសេចក្ដីសុខ ត្រជាក់ត្រជុំ គ្រប់ទិវារាត្រី ។ កម្ពុជរដ្ឋជា

---

(១) សរសេរជា ធម្ម (វ.ន.ខ. ភាគ ១ ទំព័រ ៤៥៣) គឺសភាវៈទ្រទ្រង់សត្វលោក គឺបុណ្យ, បាប, សុចរិត, ទុច្ចរិត; ហេតុ; សភាព; ធម្មតា; ប្រក្រតី; ធម្មជាតិ; ប្រាជ្ញាញាណ; គុណ; សេចក្ដីចំរើន; អារម្មណ៍ខាងផ្លូវចិត្ត; ការរិះគិត; សង្ខារ; កិរិយាមារយាទ; បរិយត្តិ; ច្បាប់ ។ល។ (ធូង)

ព្រះរាជាណាចក្រមានព្រះមហាក្សត្រ គ្រប់គ្រងមកតាំងតែពីក
កើតទឹកដីជាដំបូងមកម៉្លេះ (គឺតាំងពីសតវត្សទី១នៃគ្រិស្តសក-

---

(២) សីល ៥ ហៅនិច្ចសីល ដែលគ្រហស្ថត្រូវកាន់មានៈ ÷

ទី១— បាណាតិបាតា វេរមណី វៀរចាកធ្វើជីវិតសត្វឲ្យធ្លាក់ចុះ ;

ទី២— អទិន្នាទានា វេរមណី វៀរចាកកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ;

ទី៣— កាមេសុ មិច្ឆាចារា វេរមណី វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ;

ទី៤— មុសា វាទា វេរមណី វៀរចាកនិយាយកុហក ;

ទី៥— សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វៀរចាកផឹកទឹកស្រវឹង គឺ សុរានិងមេរ័យដែលជាហេតុ ជាទីតាំងនៃសេចក្ដីប្រមាថ ។

ឯសីល៨ ហៅឧបោសថសីល ដែលគ្រហស្ថត្រូវកាន់ដែរនោះគឺមានថែម:

ទី១— (ដដែល), ទី២— (ដដែល), ទី ៣— អព្រហ្មចរិយា វេរមណី វៀរចាកការសេពនូវមេថុនធម្ម, ទី៤— (ដដែល), ទី៥— (ដដែល), ទី៦— វិកាលភោជនា វេរមណី វៀរចាកបរិភោគក្នុងកាលខុស, ទី៧— នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធ វិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី វៀរចាកកិរិយារាំ ច្រៀង ប្រគំ មើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់ តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ, ទី៨— ឧច្ចាសយនមហាសយនា វេរមណី វៀរចាកទីសេនាសនៈខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រាជ ដែលនគរនៅមានឈ្មោះថា "នគរគោកធ្លក" ម្ល៉េះ) ។

សព្វថ្ងៃនេះ កម្ពុជរដ្ឋមានអគ្គសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងជាព្រះនិមិត្តរូបនៃព្រះរាជបល្ល័ង្កខ្មែរ ហើយនិងមានសម្ដេចព្រះឧបយុរាជព្រះ **នរោត្តម – សីហនុ** ព្រះប្រមុខរដ្ឋ ជាប្រធានសង្គមរាស្ត្រនិយម ព្រះបិតាជាតិខ្មែរទាំងមូល ។ ក្នុងនាទីយើងជាពលរដ្ឋ ជាកូនចៅនៃព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត និងសម្ដេចឪព្រះប្រមុខរដ្ឋ យើងត្រូវតែរួបរួមគ្នាជាធ្លុងមួយ រក្សាការពារព្រះរាជបល្ល័ង្កជាតិ ព្រោះព្រះរាជបល្ល័ង្កមានព្រះមហាក្សត្រជានិមិត្តរូបនេះហើយ ដែលជាស៊ីម៉ង់ផ្សាឯកភាព សេចក្ដីសុខ ចំរើនរបស់ប្រជាជាតិនិងប្រទេស តាំងអំពីបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ និងតទៅអនាគតដ៏វែងឆ្ងាយ ។

## ៣.– សទិសសព្ទនៃពាក្យ : ពារ (១)

ពាក្យពារមាន ២ យ៉ាងគឺ :

(១) ចង់ច្បាស់ សូមអានវចនានុក្រមខ្មែរភាគ ១ លើកទី ៥ ទំព័រ ៧៤៦ ។

**វារ** ជា កិ. (មកពីបាលី ឬសំស្ក្រឹតថា វារ ប្រែថា « ឃាត់, កកាំង, ទទឹងទាស់ ») = ប៉ះលើ ឬប៉ះត្រូវទាំងស្រុង (ឧ. វាររបង, ដើរវារគល់ឈើ), – ប្រទះលើគ្រោះកាច (ឧ. វារលើគ្រោះកាច), – កកាំង (ឧ. ការពារ) ។

**វារ** ជា ន. (មកពីបាលី ឬសំស្ក្រឹតថា វារ ប្រែថា « ថ្ងៃ » (ឧ. វារពុធ គឺថ្ងៃពុធ) ។

## ៤- វណ្ណយុត្ត(១) **របាទ** ( )(២)

ជាឈ្មោះវណ្ណយុត្តមួយប្រភេទដែលខ្មែរប្រើដាក់លើអក្សរតួចុង ឲ្យអក្សរតួដើមបន្ទាប់នោះ មានសូរសំឡេងញ័រ ។ គេប្រើចំពោះតែភាសាសំស្ក្រឹត ឬសំស្ក្រឹតក្លាយ (ដូចជា : តក៌, ទុគ៌ត, ទុព៌ល, ធម៌, បព៌ត, ព័ណ៌, អាថ៌) ។ តែបើមានស្រៈដែលទើសពិបាកសរសេរនោះ គេត្រូវដាក់អក្សរ រពេញតួពីលើដើមអក្សរខាងចុងវិញ (ដូចជា ទុរ្ភិក្ស, មូរ្តី, រាមកេរ្តិ៍, តិរ្ថិយ) ។

---

(១) សរសេរបាន ២ យ៉ាងគឺ វណ្ណយុត្ត ឬ វណ្ណយុត្តិ ។

(២) ចង់ច្បាស់ សូមអានវចនានុក្រមខ្មែរភាគ ២ លើកទី៣ ទំព័រ ៩៤៣ ។

## ទី២.- ព្រះមហាក្សត្រ និង ប្រជាជន

*ព្រះមហាក្សត្រដែលទ្រង់គ្រប់គ្រងប្រទេសនីមួយ ៗ(១) ព្រះអង្គជាទេពតាដោយសន្មត(២) ទ្រង់ព្រះនាមថា "ព្រះរាជា" ព្រោះទ្រង់ប្រកបដោយការសង្គ្រោះប្រជាជន ដោយប្រទានទេយ្យវត្ថុ មានព្រះវាចាគួរឲ្យ(៣) ចង់ឮ ចង់ស្ដាប់ ទ្រង់ប្រព្រឹត្តអំពើជាប្រយោជន៍សាធារណៈ ទ្រង់តាំងព្រះអង្គស្មើ ៗ គឺប្រើបុកពាឲ្យល្មមពេញចិត្តប្រជាជន ។*

*ទ្រង់តម្រង់ប្រជាជនដោយទសពិធរាជធម៌ ដោយហេតុនេះទើបទ្រង់ព្រះនាមថា បុត្តការីរបស់ប្រជាជន ។*

*ប្រជាជនដែលបានសេចក្ដីសុខដោយសារ ការគ្រប់គ្រង*

---

(១) កុំសរសេរ និមួយ ៗ ។ សុំមើលវចនានុក្រមខ្មែរភាគ ១ លើកទី ៥ ទំព័រ ៥១៧ ។

(២) គេអាចសរសេរបានទៀតថា *សម្មត* (វចនានុក្រមខ្មែរភាគ ២ លើកទី ៣ ទំព័រ១២៣៨) ។

(៣) សុំចំណាំ ។ គេសរសេរ *ឲ្យ* ឬ *ឱ្យ* យ៉ាងនេះ។ មិនត្រូវសរសេរ *ឱយ* ឬ *ឲយ* *អោយ* ដូច្នេះទេ ។ សុំអានវចនានុក្រមខ្មែរភាគ២ទំព័រ១៨៤៦។

របស់ព្រះរាជានោះ ហើយជាអ្នកមានឧបការគុណ ក៏តាំងចិត្តស្មគ្រចិត្តចំពោះការផែនដី ជួយយកអាសាផែនដីដោយស្មោះស្ម័គ្រមានស្វាមីភក្ដិចំពោះព្រះរាជា ចំពោះរាជការផែនដីឥតមានរវើរវាយ ទំរង់ទាស់ផ្លូវរាជការ យ៉ាងនេះហៅថា កតញ្ញូកតវេទី ចំពោះព្រះរាជាជាម្ចាស់ជីវិតរបស់ខ្លួន(១) ។

សម្ដេចព្រះសង្ឃរាជ **ជួន ណាត**

ស្រង់ពីកម្ពុជសុរិយា លេខ ៩ គ. ស. ១៩៤២

( ប្រឡងប្រជែងចូលរៀនថ្នាក់ទី ៦ សម័យ

ថ្ងៃទី ២៥ - ៦ - ១៩៤៨ )

## សំនួរ

១— ចូរពន្យល់ពាក្យ = យកអាសា, ស្វាមីភក្ដិ, **កត**-ញ្ញូកតវេទី ។

២— តើសំយោគសញ្ញាប្រើការយ៉ាងដូចម្ដេច ?

---

(១) អត្ថបទនេះដូចគ្នានឹងខាងដើមដែរ តែខុសគ្នាត្រង់សំនួរហើយនិងចំណងជើងអត្ថបទបន្តិច ។

៣– ចូរអ្នករាប់ព្រះនាមព្រះមហាក្សត្រនៃប្រទេសកម្ពុជា ដែលបានសោយរាជ្យតពីព្រះបាទសម្ដេចព្រះអង្គដួងមក ។

## ចម្លើយ

### ១– ការពន្យល់ពាក្យ ៖–

**យកអាសា** = ជួយឈឺឆ្អាលគេ ដោយស្ម័គ្រស្មោះអស់ពីចិត្ត ពីថ្លើម ។

**ស្វាមីភក្តិ** = (ឬស្វាមីភ័ក្តិ) សេចក្ដីស្រឡាញ់ស្មោះចំពោះម្ចាស់ ចំពោះចៅហ្វាយនាយ ។

**កតញ្ញូកតវេទី** = មកពីពាក្យ កតញ្ញូ (ជានាម ឬ គុ.) និងកតវេទី (ជានាម ឬ គុ.)

កតញ្ញូ = អ្នកដឹងឧបការគុណ ដែលអ្នកឯទៀតគេបានធ្វើហើយដល់ខ្លួន គឺអ្នកដែលមិនភ្លេច មិនរមិលគុណគេ ។

កតវេទី = អ្នកដែលបានតប ដែលគិតតែនឹងតបស្នង

សងគុណដល់អ្នកមានគុណ ។

សរុបពាក្យទាំងពីរពាក្យ គឺកតញ្ញូ កតវេទី ប្រែថាអ្នកដែលមិនភ្លេចគុណគេ ហើយគិតតែនឹងសងគុណដល់អ្នកមានគុណ (ក្នុងអត្ថបទនេះ គឺព្រះមហាក្សត្រជាអ្នកដ៏មានគុណ ដែលប្រជាជនត្រូវតបស្នងសងព្រះមហាករុណាធិគុណ ចំពោះព្រះអង្គ) ។

## ២- សំយោគសញ្ញា(១).-

ប្រែថាគ្រឿងសំគាល់អក្សរតម្រួត ។

គន្លងវេយ្យាករណ៍ គឺជាឈ្មោះវណ្ណយុត្តិមួយមានសណ្ឋានដូច្នេះ ( ˇ ) ជាជំនួសអក្សរសំយោគ សម្រាប់ដាក់លើពាក្យបាលី ឬ សំស្ក្រឹតពួកខ្លះ ដែលប្រើបំប្លែងសម្លេងឲ្យក្លាយល្អៀងពីសូរដើម ។ កាលបើមិនដាក់ ( ˇ ) នេះនាំឲ្យពិបាកថា ។ ដូច

---

(១) សុំអានវចនានុក្រមខ្មែរភាគ ២ ទំព័រ ១៤០៩ ។ បានជាខ្ញុំមិនសង្ខេបតាមវេយ្យាករណ៍ឬសង្ខេបខ្លួនឯង ពីព្រោះមិនទាន់មានសៀវភៅណាជាគោល។

ពាក្យ : ក្ស័យ, ជ័យ, ទ័ល, ន័យ, និស្ស័យ, បច្ច័យ, ពិន័យ . . . : ។

ទោះបីពាក្យដែលមានអក្សរសំយោគហើយ ប៉ុន្តែបើមិនដាក់ ( ៍ ) នេះផ្សំផងទេ នាំឲ្យពិបាកថា, ត្រូវប្រើសំយោគសញ្ញាថែមទៀត ក៏មានខ្លះ ដូចជា : ត័កិ, ព័ណ៌, ព័ទ្ធ, ពិភ័ក្តិ, ក័ត្យ, យ័ន្ត, ល័ក្ត . . . ជាដើម ។

សម្រាប់ប្រើពាក្យខ្មែរខ្លះក៏មាន ដូចជា : ខ្ញ័រ, ដ័រ, ញ័រ ទទ័រ, ទំព័រ, ទំបុ័ង, ស្បូបុ័ង ។, ភ្ល័រ, ផ្លែសង្ឃ័រ, ដើមសំព័រ ស្ពាន់ដ័រជាដើម ។

សម្រាប់ប្រើភាសាដទៃក៏មានខ្លះ ដូចជា : កុង់ត្រូល័រ, ឌីរ៉ុកទ័រ, អង់ស្ប៉ិកទ័រ ជាដើម ។

## ៣– ព្រះមហាក្សត្រ នៃប្រទេសកម្ពុជាដែលបានសោយរាជ្យសម្បត្តិជាតំណអំពីព្រះករុណាព្រះបាទសម្តេចព្រះអង្គ ដួង មក គឺ :

- ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម**
- - ដ - ព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ**
- - ដ - ព្រះបាទសម្តេចព្រះ **មុនីវង្ស**
- - ដ - ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**វរ្ម័ន
- - ដ - ព្រះបាទសម្តេចព្រះ **នរោត្តម សុរាម្រិត**

## កំណត់បំណាំ

សូមចំណាំអក្ខរាវិរុទ្ធនៃពាក្យដូចតទៅ ៖

- **ព្រះមហាក្សត្រ** = ក្សត្រ អាចសរសេរ ក្សត្រ ឬ ក្សត្រិយ៍ ។
- **នីមួយ ៗ** = កុំសរសេរ ធិមួយ ៗ ដូច្នេះ ។
- **សន្តតិ** = អាចសរសេរ សម្មតិ ដូច្នេះបាន ។ មិនត្រូវសរសេរ សន្មតិ ដូច្នេះទេ ។
- **វាចា** = គ្មានវិសាមុនទេ ។
- **ប្រព្រឹត្ត** = ជាកិរិយាសព្ទ ។ បើជានាមត្រូវសរ-

សេរ ប្រព្រឹត្តិ ប្រែថាការធ្វើតាម (ឧ. ការប្រព្រឹត្ត, សេចក្តីប្រព្រឹត្ត) ។
សូមចំណាំ ព្រ ដាក់ស្រៈ ឹ មិនមែន ស្រៈ ិ ទេ ។

– **សាធារណៈ** = ណ ខាងចុងមានយុគលពិន្ទុ(ះ)

– **ស្មើ** = គ្មាន រ ខាងចុងទេ ។

– **ឫកពា** = កុំសរសេរ រិកពា ។
ពា គ្មាន រ ខាងចុងទេ ។
កុំច្រឡំនឹងពាក្យ ឫកពារ ប្រែថាថ្ងៃ (ឧ. ចេញត្រូវឫក្សពារពេលបរ កើតលាភកុះករ ច្រើនក្រៃពេកពន់) ។

– **ទសពិធ**(១) = សរសេរស គ្មានជើង ្ស ទេ ។

---

(១) ទសពិធរាជធម៌ មាន: ១– ទាន: = ការឲ្យទាន ។ ២– សីល:

(ឆ្វង)

ពិធ សរសេរស្រះ ិ និង ធ ។

- **អាសា**= ឥតរួញរាន់ចុះទេ ។

កុំប្រឡំនឹង អសារ ប្រែថា ឥតខ្លឹម,

ឥតប្រយោជន៍ ។

- **ស្វាមីភក្តិ**= កុំប្រឡំ ភក្តិ ឬ ភ័ក្តិ (សេចក្តីគប់-

គាន) នឹង ភក្ត្រ ឬ ភ័ក្ត្រ (មុខ) ។

---

= ការរក្សាសីល ៥ ជានិច្ច។ ៣- បរិច្ចាគ = ការបំណាយព្រះរាជទ្រព្យ ទំនុកបំរុងព្រះនគរ ។ ៤- អាជ្ជវៈ = មានសេចក្តីត្រង់ ។ ៥- មទ្ទវៈ = មានសេចក្តីទន់ភ្លន់ ស្លូត សុភាពរាបសា ។ ៦- តបៈ = ការកាន់ឧបោសថសីលតាមកាលកំណត់ម្តង ៗ ។ ៧- អក្កោធនៈ = មិនកំដៅក្រហាយអ្នកដទៃ ។ ៨- អវិហឹសា = មិនបៀតបៀនអ្នកដទៃ ។ ៩- ខន្តិ = មានសេចក្តីអត់ធន់ ។ ១០- អវិរោធនៈ = មិនបំពានលើធម៌ លើច្បាប់ ។

## ទី ៣.- ដំណើរជូជកជួបនិងចេតបុត្រ(១)

ក្សិណនោះ ចេតបុត្រដើរព្រៃកំពុងត្រាប់រង្គាត់ទៅក្នុងព្រៃ ឮជូជកស្រែកទ្រហោយំរកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វដូច្នេះក្តី ចេតបុត្រក៏ស្រែកគំរាមទៅថា វ៉ុយព្រាហ្មណ៍កញ្ចាស់ ម្ដេចក៏មកយំសោករកព្រះអង្គ បើដោយអញរំពឹងគិតទៅយល់ថាព្រាហ្មណ៍កញ្ចាស់នេះឯងមករកសុំទាន ទើបខំត្រាប់មកដល់អាយសុំអ្វីមាល្យាយ តាំងពីព្រះអង្គគង់នៅក្នុងព្រះរាជវាំង ដរាបមកគង់នៅក្នុងកុដិវង្កត ខំនាំគ្នាសុំទាំងដំរីបច្ច័យនាគេន្ទ្រជាព្រះរាជទីទ័នដ៏ប្រសើរ ពួកខំសុំសព្វសុំគ្រប់ ពុំគិតប្រណីដោយក្ដីតណ្ហាលោភលន់ ទាល់តែអ្នកនគរខឹងជាកោលាហល នាំគ្នាក្រាបបង្គំទូលប្ដឹងផ្ដល់សម្ដេចព្រះវរ

---

(១) ចាប់ពីអត្ថបទទី ៣ គឺជាអត្ថបទដែលចេញហើយក្នុងការប្រឡងមធ្យមសិក្សាបត្រ ឌីប្លូម ។ ខ្ញុំមិនធ្វើការឆ្លើយសំនួរទេ ពីព្រោះកុំឲ្យប្រហែលនឹងសៀវភៅឯទៀត ហើយដើម្បីឲ្យបានចំនួនអត្ថបទច្រើនសំរាប់សិស្សានុសិស្ស យកទៅអានពិចារណា ។ នៅខាងចុងនីមួយៗ ខ្ញុំគ្រាន់តែធ្វើកំណត់សំគាល់ខ្លះផ្នែកអក្ខរាវិរុទ្ធ។

បិតាឲ្យស្ដេចបំបរបង់ព្រះអង្គចេញចាកព្រះនគរ ព្រះអង្គតោង នាំព្រះរាជបុត្រាបុត្រីនិងព្រះរាជទេវី មកគង់ក្នុងភ្នំវង្កត ។

ព្រាហ្មណ៍កញ្ចាស់នេះឯងហើយ ជាមនុស្សអបលក្ខណ៍ ខំដើរស្វះស្វែងមករកព្រះរាជបុត្រាបុត្រី ដូចកូនបក្សី គឺកុករនាល កាលឯណា បានយល់ត្រីក្នុងបឹងត្រពាំង ក្នុងរដូវប្រាំងរីងទឹកហែងហួតហើយ តែងហើរមករកចាប់ចឹកធីដកពពុះតែ អស់ ។

ព្រាហ្មណ៍អប្រិយនេះឯងជាមនុស្សអន្ធពាល កំណាចអាចតាមបំផ្លាញព្រះអង្គជាប្រាកដ វាមិនបេះរកធីបុកលក់ ទិញ ។

ព្រាហ្មណ៍ចង្រៃអើយ កុំទន្ទឹងរកព្រះអង្គឡើយ អញពុំទុកជីវិតព្រះស្ដេចឲ្យរស់នៅតទៅទៀតទេ អញបាញ់នឹងធ្នូ ឲ្យត្រូវដើមទ្រូង រួចយកថ្លើមប្រមាត់ញាំភ្ញា បូជាក្រុងពាលី ធ្វើពលីការទេវតារក្សាប្រចាំភ្នំ ឯក្បាលព្រះស្ដេចសោត អញនឹងដោតថ្វាយអ្នកតានៅនាព្រៃភ្នំនេះ ។

## សំនួរ

១– **ចូរពន្យល់ពាក្យ** : ថ្មើរជើង, មាលប្រាយ, នាគេន្ទ្រ, អបលក្ខណ៍, អន្តពាល, ពលីការ ។

២– **ចូរអ្នកសម្ពន្ធប្រយោគ** : "ឯក្បាលប្រាស្តង សោត អញ្ចឹងជោតថ្វាយអ្នកតានៅនាព្រៃក្នុំនេះ" ។

៣. **ចូរអ្នកស្រង់ចេញ** ពាក្យពហុព្យាង្គ ដែលមានព្យាង្គតម្រួត ហើយបញ្ជាក់អំពីរបៀបតម្រួតព្យាង្គ ។

មធ្យមសិក្សាប័ត្រ លើកទី ១ ថ្ងៃទី៨-៦.៥៩

## កំណត់ចំណាំ

១– **អក្ខរាវិរុទ្ធ**.–

– **ជូជក** (អានថា ជូជក់) សរសេរគ្មានបន្តក់លើ ក ទេ ។ គឺជាឈ្មោះព្រាហ្មណ៍ម្នាក់ ជាស្មូម ក្នុងរឿងវេស្សន្តរជាតក ។

– **ក្សិណា** (មកពី សំស្ក្រឹត ក្សណា, បាលីថា ខណា)

- សរសេរនឹង ក្រ ស្រៈ ះ និង ណា ។

- **កំពុង** (ជានិបាតសព្ទ) ។ កុំច្រឡំនឹង កំពង់ (ជានាម, គឺមាត់ទឹក) ។ កំពុង (ជាគុណនាម, ប្រែថា ពេញកំពូក) ។

- **ត្រាច់** (បុកណាពីដើមសរសេរ ត្រេប) ។ ដូច្នេះកុំសរសេរ ត្រេប (សុំអានវ.ន.ខ. ភាគ ១ ថ្មី ទំព័រ ៣៧១) ។

- **ទ្រហោយំ** (ទ្រហោ គ្មាន រ ចុងទេ) ។

- **ព្រះរាជវាំង** (វាំង អាចសរសេរ វាំង ដូច្នេះបាន) (វ.ន.ខ. ភាគ ២ ទំព័រ ១១៩០)

- **ដរាប** (ដ គ្មានអស្តា (៉) ពីលើទេ) - កុំច្រឡំ នឹង ដ៏ (និបាត) ។

- **ភ្នំគិរីវង្កត** (ជានាម, សរសេរ វង្កត គឺគ្មាន បន្តក់លើ ត ទេ ។ ជាឈ្មោះភ្នំមួយក្នុង

ពួកកំហិមពាន្ត) ។

- **ទីន័ង** អាចសរសេរ ទ្វីនាំង ដូច្នេះបាន (គឺទ្វីអង្គុយ, ឬទីសម្រាប់ក្សត្រិយ៍ទ្រង់ប្រថាប់) ។

- **ប្ដឹងផ្ដល់** (ប្ដឹង សរសេរទឹង ប ។ ផ្ដល់ សរសេរទឹង ផ ។ តែគេអាចសរសេរ ប្ដឹងប្ដល់ បានដែរ) (សុំអាន វ. ខ. ១. ភាគ ១ ថ្មី ទំព័រ ៦៣៨) ។

- **អបលក្ខណ៍** ឬសរសេរ អបលក្សណ៍ ក៏បាន ។

**២- សទិសសព្ទ** : នៃពាក្យ

១- ពោធិសត្វ :

- **ពោធិសត្វ** = (នាម) អ្នកដែលកំពុងខំប្រឹងបំពេញបារមី បម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។

- **ពោធិសាត់** = (នាម) គេអានថា ពោ-សាត់ ជាឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋយើង ។

២- នឹង :

- **នឹង** = (កិរិយានុគ្រោះ) ស្អែកខ្ញុំ នឹង ទៅផ្សារ ។

(ប្រាប់អនាគតកាល = le futur) ។

- **នឹង** = (គុ. ឬ កិរិយាវិសេស) អង្គុយ នឹង ថ្កល់, ដំនើទៅ នឹង, ទឹក នឹង ។

- **នឹង** = (អាយតនិបាត) កាន់ នឹង ដៃ, ភ្ជាប់ នឹង ជញ្ជាំង, ទៅ នឹង ខ្ញុំ, ដេកស៊ី នឹង គេ ។

(ត្រូវនឹងពាក្យបារាំងថា avec, au) ។

- **នឹង** = (អាយតនិបាត) ជា អកថិតកម្ម ។ ឧ. ពីម្សិលមិញ គេបាននិយាយនូវពាក្យនេះ នឹង ខ្ញុំថា . . .

- **និង** = (និបាត) ត្រូវនឹងពាក្យបារាំងថា et, អ្នក និង ខ្ញុំ, គោ និង ក្របី, សុខ និង ទុក្ខ ។

៣- លក្ខណ៍ :

- **លក្ខណ៍ ឬ លក្សណ៍** =(នាម) លក្ខណៈ (ឧ.

មនុស្សខាត លក្ខណ៍) (អាចសរសេរបាន ជា ល័ក្ខណ៍ ឬ លក្សណ៍) ។

- **ល័ក្ត ឬ ល័ខ** = (នាម) ជ័រខះរឹង (ឧ. ល័ក្តដុំ ក្រឡង់) ។

- **លក្ស្មណ៍ ឬ លក្ស្មណៈ** = (នាម) នាមព្រះអនុជរបស់ព្រះរាម (ឧ. ព្រះរាមនិងព្រះលក្ស្មណ៍) ។

៤- កល :

- **កល** = (នាម) ល្បិច, ឧបាយយ៉ាងល្អិត (ឧ-បាយកល) ។

- **កល់** = (កិ.) ទ្រពីក្រោម (ឧ. ដាក់កំណល់ កល់ពីក្រោម) ។

x

x x

## ទី ៨.— រឿងចចកនិងស្គរ

មានចចកមួយស្រេកឃ្លានខ្លាំង ដើរស្វះស្វែងរកអាហារ ត្រមង់ត្រមោច កាត់ព្រៃ រុក្ខា លតាវល្លិ គិរីបពិត បានឃើញស្នាមសមរភូមិចាស់មួយ ដែលគង់ទ័ពច្បាំងតតាំងគ្នា ។ សេនាទាហានដែលច្បាំងគ្នា ហើយដើរបាត់ទៅ បានចោលស្គរមួយទើរនៅលើមែកឈើ ៗ មែកឈើនោះ កាលបើមានខ្យល់បក់មក ក៏ហាក់ដូចជាទៅវាយស្គរនោះឮសូរទូង ៗ ។

ចចកឮហើយ ភិតភ័យតក្កមាញ័ររន្ធត់សព្វសព៌ាង្គកាយ គិតថា “ ឱ អន្តរាយដល់ហើយ បើនៅឆ្ងាយទៅក៏នឹងគេចចេញឲ្យផុត តែណ្ហើយចុះ អាត្មាអញមិនគួរប្រញាប់ប្រញាល់លះបង់ព្រៃ ជាទីឋានដ៏មនោរមដីដូនដីតាទេ ព្រោះថា ក្នុងគ្រាមានអាសន្ន ឬមានសេចក្ដីភ័យមកដល់ ទស្សនវិទូមិនធ្វើកិច្ចការអ្វី ៗ ដោយរហ័សពេក គេពិចារណា គេមិនក្ដៅក្រហាយ កើតមានវិប្បដិសារីឡើយ ។ បើដូចនេះ អាត្មាអញត្រូវចូលទៅមើលឲ្យបច្ចក្ខនឹងភ្នែក នូវសំឡេងនេះសិន ” ។

ចចកសំដែងសេចក្ដីក្លាហានយ៉ាងម៉ឺងម៉ាត់ ដើរតម្រង់ទៅជិត ឃើញស្គរកញ្ចាស់មួយទេរនៅលើមែកឈើ ពិនិត្យឃើញយ៉ាងប្រត្យក្សថា កាលណាមានខ្យល់បក់មក មែកឈើដែលយោលទៅមក ទៅប៉ះនឹងស្គរ ហាក់ដូចជាគេវាយ ឮស្នូរទូងៗ កាលណាឥតខ្យល់ ក៏បាត់ឮស្នូរទៅ ។

ចចកយល់ច្បាស់ជាស្គរហើយ ក៏ដើរចូលទៅជិតយកដៃវាយលេងដោយក្ដីបំណងយ៉ាងបីតិរីករាយ ហើយគិតថា « នុស្គរនេះ បានជាភោជនាហារច្រើនណាស់ ពីយូរយារណាស់មកហើយ អាត្មាអញពុំដែលមានភ័ព្វវាសនា បានអាហារច្រើនម៉្លេះទេ ខាងក្នុងប្រហែលជាពោរពេញទៅដោយសាច់ និងខ្លាញ់ច្រើនអនេកប្បការហើយ » ។

ខណៈនោះ ចចកក៏ខំប្រឹងកកេរចោះទម្លុះស្បែកពាសស្គររឹងក្រៀមក្រោះធ្លុះចូលទៅខាងក្នុង ដោយចិត្តសោមនស្សក្រៃលែង ដល់ហើយគ្មានឃើញអ្វី កើតក្ដីអាក់អន់ចិត្ត

ពោលជាពាក្យស្លោកថា: « ខួងៗជួបស្គរ ខានក្ដងប្រ-ហោងធ្ងន់ » ។

## សំនួរ

១. **ចូរពន្យល់ពាក្យ** សមរភូមិ, វិប្បដិសារី, វត្ថា, លតា, បច្ចក្ខ, ប្រត្យក្ស, អនេកប្បការ ។

២- **ចូរធ្វើសម្ពន្ធពាក្យ** ក្នុងប្រយោគ « បើដូចនេះ អាត្មាអញត្រូវចូលទៅមើលឲ្យបច្ចក្ខនឹងភ្នែក នូវសំឡេងនេះសិន » ។

៣- **ចូររកសទិសសព្ទ** នឹងពាក្យ « ការ » ហើយចងជាប្រយោគ ។

៤- **រឿងនេះ** មានគតិយ៉ាងណា ?

មធ្យមសិក្សាបត្រ

លើកទី ២ ថ្ងៃ ១-៩-៥៩

## កំណត់បំណាំ

១. អក្ខរាវិរុទ្ធ .–

– **វល្លិ** សរសេរ វ – ល្លិ (អានថា វ័ល) ។

– **ទើរ** មាន រ ខាងចុង ។

– **មនោរម** (រម សរសេរ រ និង ម ។ កុំច្រឡំ នឹង រម្យទម ដែលអាចសរសេរជា រមទម ក៏បាន) ។

– **ជីដូនជីតា** (មិនមែន ជិ ដូន ជិ តា ទេ) ។

– **អាសន្ន** សរសេរ អា-ស័ និង ន្ន ។

– **រហ័ស** អាចសរសេរក្លាយជា រហាស់ ក៏បាន (អាន វ.ន.ខ. ភាគ ២ ទំព័រ ៩៣៤) ។

– **សំឡេង** មិនសរសេរ សម្លេង ដូច្នេះទេ ។ (អាន វ.ន.ខ. ភាគ ២ ទំព័រ ១៤១៥) ។

– **តម្រង់** សរសេរតម្រួត មកពីពាក្យ ត្រង់ ៗ ពីមុន សរសេរ តំរង់ ឬ ដំរង់ ឬ ដម្រង់ ដូច្នេះបានៗ

- **ពិនិត្យ** *សរសេរ ពិ-និ និង ត្យ ។*
- **ប្រត្យក្ស** *អាចសរសេរជា ប្របក្ស បាន ។ ដូចជា បច្ចក្ខ ឬ បច្ចក្ស ។*
- **ម្ល៉េះ** *មិនមែនសរសេរ ម្ល៉ែះ ដូច្នេះទេ ។*

២- **សទិសសព្ទ** *នៃពាក្យ :*

១- នៅ.-

- **នៅ** *ជាកិ. ប្រែថា ឋិត, ស្ថិត, មាន (នៅឯណា? នៅផ្ទះ) ។*
- **នៅ** *ជា កិ.វិសេស ប្រែថា ដែលមិនទាន់, ដែលមានទៀត (អស់ហើយឬនៅ? នៅ!) ។*
- **នូវ** *ជា និបាត ប្រែថា និង, ហើយនិង (ព្រះរាជ-វង្សានុវង្ស និងមន្ត្រីធំតូច នូវអស់ប្រជាជនទាំងពួង) ។*
- **នូវ** *ជា អា.និ. គឺពាក្យប្រាប់ដំណើរសម្រេចអំពើ ដែលគេត្រូវធ្វើ (បុគ្គលធ្វើនូវអំពើល្អ ដោយ*

កាយ វាចា ចិត្ត ទើងបាននូវផលល្អ) ។

២- ណោះ.–

– **ណោះ** វិ.ស. គឺពាក្យសម្រាប់បង្ហាញ ចង្អុលអ្វីៗ ដែលនៅឆ្ងាយ តែប្រាកដ (សំបុត្រនោះ, អ្នកនោះ) ។

– **ណុះ** សព្វ. គឺពាក្យសម្រាប់និយាយចង្អុលប្រាប់នូវ អ្វីៗ មើលទៅឃើញ ប៉ុន្តែមិនឆ្ងាយពេកទេ (បន្ទាត់អ្នកណានុះ) ។

– **ណុ៎ះ** សព្វ. ប្រែថា ហ្នឹង គឺពាក្យសម្រាប់និយាយ ចង្អុលនាមសព្វ ដែលនៅឃ្លាតឆ្ងាយច្រើនពីខ្លួន តែមើលទៅឃើញ (អ្នកណានុ៎ះ!? នុ៎ះន៎ ! ។

៣- ក៏.–

– **ក** ជានាម គឺអវយវៈដែលតពីក្បាលទៅស្មា (កដៃ- កជើង – កមនុស្ស) ។

- **ក** ជាកិ. ប្រែថា តាំងផ្តើម តាំងធ្វើ (កសាង; កកើត, កកូម) ។
- **ក៏** ជា និ. សម្រាប់និយាយតប្រយោគ (អ្នកក៏ទៅ, ខ្ញុំក៏ទៅ)

**សូមចំណាំ**

- **កករ** (កករប្រេង, បិត្តកករល្អក់)
- **កកូរ** (សម្ល កកូរ)
- **កកេរ** (កកេរពោត)

x

x x

## ទី៥- បុណ្យភ្ជុំបិណ្ឌ

បុណ្យភ្ជុំបិណ្ឌ ជាបុណ្យដែលខ្មែរទាំងប្រទេសបានធ្វើគ្រប់គ្នាឥតមានខាន ដើម្បីឧទ្ទិសរំលឹកដល់បុព្វបុរសនិងញាតិសាលោហិតដែលបានទៅកាន់បរលោក ។ បុណ្យនេះ ធ្វើបានតែដប់ប្រាំថ្ងៃគត់ គឺថ្ងៃមួយរោចខែភទ្របទ ទៅទល់នឹងថ្ងៃដាច់ខែ ។

ឧត្តមកិច្ចនេះ ពលរដ្ឋខ្មែរបានប្រកាន់យកតាំងពីបុរាណកាលរៀងមក ព្រោះខ្មែរគ្រប់រូបគោរពអ្នកមានគុណ គោរពព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ មានសាមគ្គីធម៌រាប់រកគ្នា ដោយស្និទ្ធស្នាលក្នុងពិធីភ្ជុំបិណ្ឌនេះ ។

នៅគ្រប់តែវត្តអារាមក្នុងព្រះរាជអាណាចក្រ ឧបាសកឧបាសិកា ពុំគ្រាន់តែឧទ្ទិសផលបុព្វការីបុគ្គលទាំងឡាយរបស់ខ្លួនទេ ថែមទាំងឧទ្ទិសផលដល់ដួងវិញ្ញាណនៃខេមរកុមារនិងខេមរជនអ្នកស្នេហាជន អ្នកស្នេហាជាតិទាំងឡាយ ដែលបានទទួលមរណភាពនាសមរភូមិក្នុងការបំរើមាតុប្រទេស និងឧទ្ទិសផលវិញ្ញាណក្ខន្ធនៃអ្នកនិពន្ធនិងកវីខ្មែរនានា ដែលបានបំរើអក្សរសាស្ត្រនិងវប្បធម៌ជាតិ ឲ្យមានកេរ្តិ៍ដំណែលរុងរឿងស្តុកស្តម្ភជាតិយោគ្យភាព ។

គំនរបុណ្យដែលកើតឡើងអំពីអាមិសទាន និងធម្មទានក្នុងបុណ្យភ្ជុំបិណ្ឌនេះ ពលរដ្ឋខ្មែរទាំងមូលបានឧទ្ទិសថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រិយានី

សូមព្រះអង្គទ្រង់ស្ថិតជាបរមសុខឈ្នះអស់មារសត្រូវ ហើយសូមកុសលទាំងនោះ ដឹកនាំមិត្តជាតិខ្មែរ ឲ្យរឹតតែស្រឡាញ់ជាតិដោយស្វាមីភក្តិ ។

ជាពិសេស សូមឥដ្ឋមនុញ្ញផលនេះជួយប្រោន ជួយកម្ចាត់អំពើបំផ្លាញជាតិឲ្យវិនាសសាបសូន្យ ហើយសូមឲ្យសាមគ្គីធម៌គង់វង់ប៉ុនជាបរិបូណ៌ ហាក់ជាខ្សែវេញជាផ្តុំមួយ ។

## សំនួរ

១– **ចូរពន្យល់ពាក្យ** បុត្រ, កវី, ភិយ្យោភាព អាមិសទាន, ឥដ្ឋមនុញ្ញផល ។

២– **ចូរសម្ពន្ធពាក្យក្នុងឃ្លា** " ឧត្តមកិច្ចនេះ ពលរដ្ឋខ្មែរបានប្រកាន់យក តាំងពីបុរាណ រៀងមក " ។

៣– **ពាក្យបរិបូណ៌** គេអាចសរសេរបានប៉ុន្មានយ៉ាង? ចូរពន្យល់ហើយបញ្ជាក់ដោយឧទាហរណ៍ជាឃ្លាផង ។

## ៤- អ្វីខ្លះដែលជាអគ្គ នៃព្រហ្មវិហារតាមព្រះពុទ្ធសាសនា ?

មធ្យមសិក្សាប័ត្រ

លើកទី១ ថ្ងៃ២៨ - ៣ - ៦០

### ចម្លើយ(១)

១- ពន្យល់ពាក្យ :-

- **បុព្វ** ជាគុ. ប្រែថាមុន, ខាងដើម, ពីមុន (ឧ.បុព្វ-កថា, បុព្វកម្ម, បុព្វណ្ហសម័យ, បុព្វនិមិត្ត, បុព្វនិវាស, បុព្វជាតិ, បុព្វបទ, បុព្វយោគ ឬបុព្វប្រយោគ, បុព្វបុរស, បុព្វសិទ្ធិ, បុព្វហេតុ...) ។

- **កវី** ជានាម (មកពីសំ.ធា.ថា កវិ) គឺអ្នកប្រាជ្ញដែលចេះតែងឆន្ទ កាព្យឃ្លោង ឬអ្នកប្រាជ្ញខាងសំដី ។

---

(១) ចំពោះអត្ថបទនេះ ខ្ញុំធ្វើចម្លើយតែ៣ទេ ដើម្បីទុកជាឯកសារជូន។

កុំថា អ្នកកវី ៗ គេថា អ្នកនិពន្ធ និងកវី ៗ

– **ភិយ្យោភាព** ជានាម (មកពីបា· ភិយ្យោ + ភាវ) ប្រែថា ដំណើរច្រើនក្រៃលែង, ភាវៈលើសលែង ៗ គេប្រើជាគុ. ក៏បាន (មាន-អំណាចជាភិយ្យោភាព) ៗ

– **អាមិសទាន** ជានាម (មកពី បា. អាមិស + ទានៈ) អាមិស ប្រែថាសាច់ (ដែលប្រើជាអាហារ) – ទានជាចតុប្បច្ច័យ គឺ ចីវរ (គ្រឿងស្លៀកដណ្ដប់), បិណ្ឌបាត (អាហារ), សេ-នាសនៈ (លំនៅ) និងគិលានភេសជ្ជៈ (ថ្នាំរំងាប់ជំងឺ, រំងាប់រោគ) ៗ

– **ឥដ្ឋមនុញ្ញផល** ជានាម (មកពី បា. ឥដ្ឋ + ម-នុញ្ញផល) ប្រែថាផលជាទីពេញចិត្ត ដែលបានសម្រេចដូចបំណង ៗ

២- ពាក្យ បរិបូណ៌ ._

គេអាចសរសេរបាន ៣ យ៉ាង :

– **បរិបូរ** ជាគុ. (ម្ហូបនេះបរិបូរណាស់)

– **បរិបូណ៌** ជាគុ. ឬ កិ. (ស្រូវបរិបូណ៌, ព្រះមហោ-សថមានបញ្ញាបរិបូណ៌អស្ចារ្យ, ព្រះពោធិសត្វបរិបូណ៌ទៅដោយបញ្ញា) ។

– **បរិបូរណ៌** ជានាម (អ្នកបរិបូរណ៌ដោយបញ្ញារមែងតែឈ្នះឧបសគ្គនានា) ។

៣_ អង្គនៃព្រហ្មវិហារ តាមព្រះពុទ្ធសាសនា .–

ព្រហ្មវិហារ ជានាម ប្រែថា ធម៌ជាទីនៅនៃព្រហ្ម ធម៌ជាលំនៅនៃចិត្តដ៏ប្រសើរ មាន ៤ យ៉ាងគឺ :

១ – **មេត្តា** ផ្សាយសេចក្ដីរាប់អានទៅរកសព្វសត្វ ។

២ – **ករុណា** ផ្សាយសេចក្ដីអាណិតទៅរកសព្វសត្វ ។

៣- មុទិតា ផ្សាយអំណរទៅគេសព្វសត្វ ដែលបានសេចក្ដីចម្រើន គឺមានអំណរនឹងគេបានសុខចម្រើន ។

៤- ឧបេក្ខា ផ្សាយសេចក្ដីស្មោះស្មើទៅគេសព្វសត្វ។

## កំណត់បំណាំ

១- អក្ខរាវិរុទ្ធ .–

– រំលឹក អាចសរសេរ រំឭក ក៏បាន ។

– ស្និទ្ធស្នាល (ស្និទ្ធ សរសេរ ស្និ និង ទ្ធ) ។

– អារណាចក្រ អាចសរសេរ អាណាបក្ក ក៏បាន។

– ឧបាសក ឧបាសិកា (សក សរសេរឥតបន្តក់ទេ ។ សិកា គ្មានវ ខាងចុងទេ) ។

– ឧទ្ទិស សរសេរ នឹងស្រៈ ិ ។

– ទាំងឡាយ អាចសរសេរ ទាំងហ្លាយ ដូច្នេះក៏បាន ។

( អាន វ ឧ.១. ភាគ ១ ទំព័រ ៤៦១ ) ។

- **ភូមិន្ទ** (មិន្ទ សរសេរ មិ និង ន្ទ) ។
- **បម្រើ** (ក្នុង វ.ន.វ. ភាគ ថ្មី ទំព័រ ៥៥៥) មិនសរ-សេរ បំរើ ដូច្នេះទេ គឺមកពីពាក្យ ប្រើ ទៅជា បម្រើ គឺសរសេរតម្រួតដូចគ្នា ។ បម្រើ បម្រាស់ (បម្រាស់ មកពីពាក្យ ប្រាស់)។
- **ស្តុកស្តម្ភ** (ស្តម្ភ សរសេរ ស្ត និង ម្ភ) ។
- **ភិយ្យោភាព** (មិនសរសេរ ភេយ្យោភាព ដូច្នេះទេ) ។
- **គំនរ** (សរសេរ ន និង រ ។ ដូចជា គរ ទៅជា គំនរ) ។
- **ព្រះមហាក្សត្រិយានី** (អាន ក្សត្រិយ៉ាណី តែសរសេរជា ក្សត្រិយានី ដូច្នេះ) ។
- **ស្ថិត** អាចសរសេរជា ឋិត ដូច្នេះបាន ។
- **រឹត** (សរសេរ រ ឹ និង ត) ។
- **កម្ចាត់** (អាន វ.ន.វ. ភាគ ១ ថ្មី ទំព័រ ២៣) មិនសរ-

សោរ កំបាត់ដូច្នេះទេ ។ កម្ចាត់ មកពីពាក្យ ខ្ចាត់ ។ គឺត្រូវសរសេរ តម្រួតដូចគ្នា) ។

២- **សទិសសព្ទ** នៃពាក្យ ៖

១- សព្វ ៖ –

– **សព្វ** ជា គុ. ឬ កិ.វិ. ប្រែថា ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់, ទូទៅ, ពល់ (ឃើញសព្វ, ចេះសព្វ) ។

– **សព្វ** ជា កិ. មានន័យថា ពេញ, គាប់, ស្ម័គ្រ ស្មោះ, ត្រូវ, ឥតខុស, ឥតទាស់ (សព្វព្រះទ័យ) ។

– **សព្វ** ជា វិ.ស, ឬ គុ. ប្រែថា ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់, គ្រប់យ៉ាង, ទូទៅ, ពល់ (សព្វគុណ = គុណសម្បត្តិគ្រប់យ៉ាង ។ សព្វញ្ញុតញ្ញាណ, សព្វញ្ញុពុទ្ធ, សព្វញ្ញូ, សព្វយុត្ត, សព្វលោក,

សត្វបែនៈ, សត្វវិទូ ។ល។ ...) ។

- **សព** ជា នាម ប្រែថា ខ្មោចស្រស់, រូបបុគ្គលស្លាប់, សាកខ្មោច (តំកល់សព, ធ្វើបុណ្យសព) ។

- **សប់** ជា កិ. ស្រូបដោយស្នប់ (សប់ទឹក, សប់កង់ឡាន) ។

២- រថ.—

- **រថ** ជា នាម ប្រែថា រទេះទឹមសេះ (រថសេះ, រាជរថ, រថយន្ត) ។

- **រត់** ជា កិ. ប្រែថា ស្ទុះដោយលឿន (រត់ខ្ចិត) ។

៣- រដ្ឋ.—

- **រដ្ឋ** ជា នាម ប្រែថា ដែន, ប្រទេស (រដ្ឋធម្មនុញ្ញ, រដ្ឋធានី) ។

- **រតន៍ ឬ រត្ន** (រតន ឬ រត្ន) ជា នាម ប្រែថា កែវ,

ពេជ្រ, ត្បូងគ្រប់ប្រភេទ (ព្រះរតនត្រ័យ, ពុទ្ធ-
រតនៈឬ ពុទ្ធរត្ន) ។

៤- ជន.–

– **ជន** ជានាម ប្រែថា សព្វសត្វដែលកើតក្នុងលោក មនុស្ស, អ្នកផង (បណ្ដាជន) ។

– **ជន់** ជាកិ. ប្រែថា ឡើងសាយភាយ (ទឹកជន់)។

៥- មារ.–

– **មារ** ជានាម ប្រែថា ដំណើរពាំង, ការសម្លាប់, សេចក្ដីស្លាប់, អ្នកពាំង, ឈ្មោះទេវបុត្រ ដែលជាសត្រូវចំពោះព្រះពុទ្ធ (មារដ្រែក) ។

– **មា** ជានាម (ឪពុកមា) ។

៦- រឹត.–

– **រឹត** ជាកិ. ធ្វើឲ្យតឹង (រឹតខ្សែ) ; ចំរើនឡើង, ខ្លាំងឡើង (ជំងឺរឹត, រឹតដៃ) ។

– **រឹត** ជានាម (ស៊ីករឹត) ។

– **រឹត** រឹតតែ ជាទិ. កាន់តែ, ចេះតែ, (រឹតខូច, រឹតតែខ្លាំងឡើង) ។

– **រឹតត្បិត** ជាកិ. ប្រិតប្រៀប, ប្រិតខ្លាំង ។

– **រិទ្ធិ ឬ ឫទ្ធិ** ជានាម ប្រែថា សេចក្តីសម្រេច, អំណាច, សេចក្តីអស្ចារ្យ, រុងរឿង (ប្រឡងឫទ្ធិ, ប្រើឫទ្ធិអំណាច) ។

x

x x

## ទី ៦– ជីវិតសាបសូន្យក្នុងអាថ៌កំបាំងលើនាវា

ព្រះចន្ទរះនៅប៉ប្រេះមាត់ព្រៃ ពុំទាន់អស្តង្គតនៅឡើយទេ ។ អរុណរង្សីនៅភ្លឺស្រាល ចាំងមកលើព្រះរាជធានី ជាទីអវសាន ។ មេឃស្រឡះថ្លាយង់រកពពកមួយដុំគ្មាន ស្រមោលធម្មជាតិចុះចូលទៅក្នុងគង្គា ឃើញវែងអន្លាយ ហើយខ្មៅស្ងប់ ៗ ។

ក្រឡាហោមគង់ អង្គុយនៅត្រមោចឯកឯង លើនាវា មានទឹកមុខក្រៀមក្រំជាពន្ទឹក ចំប្រឹងសំឡឹងមើលទៅត្រើយខាងលិច ឃើញប៉មកំពែងព្រះបរមរាជវាំង និងប្រាង្គប្រាសាទ ក្ចិចញ្ចាច វិចិត្រដោយក្បាច់ចេនាផ្សេង ៗ មានបែបតាពងនិងកំពូលមណ្ឌលខ្ពស់ត្រដែតឡើងទៅលើ ៗ

កប៉ាល់បើកឃ្លាតពីវត្តឧណ្ណាលោម ឆ្ពោះត្រង់ទៅឯជើងហើយ ៗ ព្រះសុរិយា ក៏លិចស្រឹមបាត់ទៅ ពេលព្រលប់ទិតបូលមកដល់ភ្លាម ធ្វើឲ្យស្រអាប់គ្រប់ទិសមួយរំពេច ៗ មិនយូរប៉ុន្មាន យប់ងងឹតក៏បូលមកត្រដាងគ្របលើផែនពសុធា មើលអ្វីលែងឃើញទាំងអស់ ៗ

មុខគួរឲ្យសង្វេគពន់ពេក នៅលើកប៉ាល់ ក្រឡាហោម-គង់ ដៃទាំងពីរជាប់ខ្នោះ ចំគ្រដរផ្គងឡើងទូរអញ្ជលី ក្រាបថ្វាយបង្គំលាព្រះបរមរាជាពីចម្ងាយ ៗ សេចក្ដីស្នេហាជាតិមាតុភូមិនិងព្រះមហាក្សត្រ នៅតែជិតជាប់នឹងដួងចិត្តបណ្ឌិតនេះជាដរាប ពុំមានប្រាសចាកទៅណាបន្តិច ៗ

ក្រឡាហោមគង់លើកដៃប្រណម្យដោយលំបាក ទឹកភ្នែកហូរសស្រាក់ធ្លាក់មកលើដើមទ្រូង សស្រេងសស្រៃ អង្គុយសញ្ជឹងគិតថា : " ខ្លួនអាត្មាអញ ទៀងជាស្លាប់នឹងដៃបារាំងក្នុងគ្រានេះហើយ ៗ ប្រហែលជាឪអញពុំបានជ្រាបផងទេ ៗ គំនិតនេះជាសេចក្ដីព្យាបាទរបស់ជាតិបរទេស ធ្វើដោយអាថ៌កំបាំង ពុំឲ្យនរណាដឹង " ៗ

សញ្ជឹងគិតដូច្នេះហើយ ក្រឡាហោមគង់ក៏ធ្វើតឧកាសប្រសិទ្ធិពរថ្វាយបន្តិច ៗ ចំពោះព្រះកូសក្ក ថា : សូមឲ្យព្រះអង្គស្ថិតនៅក្នុងសិរីរាជសម្បត្តិប្រកបដោយសុខមាលភាពនិងវឌ្ឍនភាពដ៏រុងរឿងតទៅ ៗ ខ្លួនទូលព្រះបង្គំជាខ្ញុំពុំបាននៅយកអាសាព្រះអង្គទៀតទេ មុខជានិរាសប្រាសចាកពីព្រះអង្គក្នុងពេលឥឡូវនេះហើយ ៗ

**រីម - គីន**

( ស្រង់ពីក្រឡាហោមគង់ ភាគ ២ )

## សំនួរ

១- **ចូរពន្យល់ពាក្យ** *អរុណរង្សី, ប្រាង្គប្រាសាទ*

*ព្រះកូសក្ក, សុខុមាលភាព ។*

២- **ចូររកវេវចនសព្ទ** *នៃពាក្យទាំងនេះ ៖*

*អរុណរង្សី, ពសុធា, ប្រណម្យ ។*

៣- **ចូរអ្នកអធិប្បាយអំពីមុខងារ** *សំរេចអំពើ*

*របស់សកម្មកិរិយា និងអកម្មកិរិយា*

*ហើយចូរស្រង់ក្នុងពាក្យនេះដាក់ដោយឡែក*

*ពីគ្នា ព្រមទាំងកិរិយាសព្ទដែលអាចប្រើ*

*បានក្នុងប្រភេទទាំងពីរ ប្រសិនបើមាន ។*

មធ្យមសិក្សាប័ត្រ

( លើកទី ២ ថ្ងៃ ២០-៦-៦០ )

## កំណាត់បំណាំ

១- **អក្ខរាវិរុទ្ធ**.-

- **ទិន្នករ** ( *អានថា ទិន - នាក់ - ករ ឬ ទិ - នាក់ -*

ករ) សរសេរ ទ្ធិ និង ធ ។ ក៏ មានរៀ
ខាងចុង ។

- **អរុណ** (មិនមែន អារុណទេ) សរសេរ រុ និង ណ ។

- **អវសាន** (សាន សរសេរ សា និង ន) កុំ ប្រឡំនឹងពាក្យ សាន្តត្រាណ, សុខសាន្ត, កម្សាន្ត (មកពីក្សាន្ត) ។

- **ក្រៀមក្រំ** (ក្រំ មិនសរសេរ ក្រ និង ម ទេ) គេថា ក្រំខ្លួន, ក្រំចិត្ត ។ កុំប្រឡំនឹង ក្រម (ក្រិត្យក្រម, ក្រមការ) ។

- **ប្រាសាទ** (កុំប្រឡំនឹង ប្រសាទ) ។

- **កប៉ាល់** (មិនមែន កុ ប៉ាល់ ដូច្នេះទេ) ។

- **ឧណ្ណាលោម** (សរសេរ ឧណ្ណា + លោម ។ អានថា ឧណ្ណា + ឡោម) ។

- ស្រីម (អាចសរសេរ ស្រិម ក៏បាន) ។

- ឯជីត (ជឹត សរសេរ ឯ និងស្រៈ ី) ។

- អញ្ជលី (អាចសរសេរ អញ្ជលិ ក៏បាន ។ ខ្លះ សរសេរ អញ្ជលី) ។

- ដួងចិត្ត (មិនសរសេរ ឌួង ដូច្នេះទេ) ។

- បណ្ឌិត (កុំច្រឡំ នឹង បណ្ឌិត្យ ដែលជាគុ. ឬ នាម ប្រែថាការៈនៃបណ្ឌិត, សភាព, ឋាន, ទី, តំណែងនៃបណ្ឌិត ។ ឧ. បណ្ឌិត្យសភា, ពុទ្ធសាសនបណ្ឌិត្យ) ។

- ប្រណាម្យ កិ. (សរសេរ ណា និង ម្យ ។ កុំច្រឡំនឹង ប្រណាម ជានាម) ។

២- វេវចនសព្ទ នៃពាក្យ :

១- អរុណរង្សី (មកពីអរុណ + រង្សី ឬ រស្មី) = រស្មីព្រះអាទិត្យពណ៌មាស) ។

– សុរិយារង្សី, ទិនរង្សី. អាទិច្ចរង្សី, សូរ្យរង្សី, ភាណុរង្សី, រវិរង្សី, ហរិរង្សី ។

– អរុណប្រភា, អរុណរស្មី ។

**២– ពសុធា** (មកពី សំ. ធា. វសុធា. វ>ព ជា ពសុធា) ។

ផែនដី, ពិភពលោក, ពសុន្ធរា, វសុន្ធរា, បឋវី, ប្រឹថពី, មណ្ឌលដី, ធរណី, មហី, មេទនី, វិសុន្ធរី, រតនគព្ភា ។

**៣– ប្រណាម្យ** (កិ. លើកកម្បង់អញ្ជលីសំពះ)

–លើកដៃសំពះ, សំពះ, ធ្វើអភិវន្ទកិច្ច, អភិវាទនកិច្ច, វន្ទនកិច្ច, ថ្វាយបង្គំ ។

**៣– សទិសសព្ទ** នៃពាក្យ :

១– វិញ.–

– **វិញ** : និ ប្រែថា ទៀត, ដូចដែល (មកវិញ, ទៅ

វិញ); ជាជាង, ស្រួលជាង, ទេតើ, (យកនេះវិញ); ថែមទៀត, មួងទៀត, ដដែលទៀត (វិញទៀត) . . .

– **វេញ** កិ. ប្រែថា គ្រងបញ្ចូលចូលគ្នា (វេញខ្សែ); រួមគំនិតគ្នាតែមួយ (វេញគំនិតគ្នា) ។

២– អាបិ.–

– **អវចិ** ជានាម (អាចំកំបាំង) ។

– **អវធិ** ឬ អាទិ ជានាម ប្រែថា ដើម, ខាងដើម, ដើមដំបូង (ឧ. មានដូចេះជាអាទិ, ដើមអាទិ, នាំអាទិ៍) គេសរសេរ អាទ្យ ក៏បាន ។

៣– និរ.–

– **នរ** ជានាម (មកពី សំ. ធា. នរ) ប្រែថា មនុស្សជន (នរណាហ្នឹង!) ។

– **នី** ជានិ. សំរាប់ប្រើថ្នូនពាក្យ នុះ, ឯណោះ (នុះនី! ឯណោះនី!) ។

៤- សម្បត្តិ.-

- **សម្បត្តិ** ជានាម ប្រែថា សេចក្ដីសម្រេច, ការ-សមប្រកប, សេចក្ដីសុខ, លំអ, ទ្រព្យ, ធន-ធាន (មានសម្បត្តិ, សម្បត្តិសម្បូណ៌) ។

- **សម្បទ** (ឬ សម្បទា) ជានាម ប្រែថា ការដល់ព្រម, ការសមប្រកប (គុណសម្បទ) គេអាចសរសេរ **គុណសម្បត្តិ** ដូច្នេះក៏បាន ។

៥- រុង.-

- **រុង** ជាគុ. ប្រែថា ធំ, ដែលចំរើន (ភពរុង, ភព-ធ្លារ, នាអ្នករុងរក្សាធ្លារ) ។

- **រុងរឿង** ជាគុ. ប្រែថា ភ្លឺត្រចះ, ឆើត ។

- **រុងរោចន៍** ជាគុ. ប្រែថា ដែលរុងរឿង, ភ្លឺផ្លេក, ពណ្ណរាយ) ។

- **រុងរាំង** ជាកិ ឬ កិ. វិ. (ធ្វើរុងរាំង) ។

- **រង់** ជាកិ. ប្រែថា បង្អង់ចាំ, ឈប់បង្អង់ (រង់ចាំ

បន្តិចសិន ) ។

– **ទង់ដឿង** ជានាម គឺឈ្មោះរោគមួយកើតត្រង់ចុងម្រាមដៃ ជើង បណ្ដាលឲ្យឈឺចាប់ពេកខ្លាំង ។

– **ទន្ត** ជានាម គឺឈ្មោះដ័រម៉្យាង (ដ័ររង្គ)

– **ទន្តៈ** ជានាម ប្រែថា ការរីករាយសប្បាយ, ល្បែងរបាំ, ល្ខោន (រង្គសាល, រង្គភូមិ) ។

x

x x

## ទី៧– យុវជនខ្មែរ

យុវជនខ្មែរទាំងអស់ ទោះប្រុសក្ដី ស្រីក្ដី ជាកម្លាំងមួយផ្នែកយ៉ាងសំខាន់ ក្នុងការបម្រើប្រទេសជាតិមាតុភូមិ ។ យុវជនយើងត្រូវតាំងសតិសម្បជញ្ញៈឲ្យភ្ញាក់រលឹកជានិច្ច ព្រមទាំងមានសតិអារម្មណ៍ខ្ពង់ខ្ពស់ប្រសើរឧត្តុង្គឧត្តម តែត្រូវមានសន្តានចិត្តបេះសន្តោស មានអធ្យាស្រ័យ បរិសុទ្ធហ្មត់ហ្មងបេះសាមគ្គីជិតស្និទ្ធ ស្រឡាញ់រាប់អានរកមិត្តភក្តិ មិនប្រទូស្តឬប្រមាថមើលងាយយុវជនដទៃ មិនសេពគប់ស្ម័គ្រស្មាគមជា

មួយទឹងមនុស្សពោលអបលក្ខណ៍ និងមិនប្រព្រឹត្តល្បែងពាលា ដែលនាំមកនូវទោសពៃរ៍ដល់ខ្លួនឡើយ ។

នៅតាមជនបទស្រែចំការ ឬនៅតាមរោងចក្រឧស្សាហកម្ម យុវជនជាកសិករ ឬជាកម្មករ ត្រូវបញ្ចេញសមត្ថភាពឲ្យអស់ពីចិត្ត ប្រឹងប្រែងរវៀសរវៃប្រកបការងារ ដែលជាភារកិច្ចរបស់ខ្លួន មិនស្ទាក់ស្ទើរត្អូញត្អែរ ដោយខិតខំបង្កើតផលិតផលគ្រប់ជំពូក ឲ្យបានសម្បូណ៌ហូរហៀរច្រើនជាអនេកប្បការ ដើម្បីសាងសេដ្ឋកិច្ចជាតិឲ្យបានចម្រើនលូតលាស់ឆាប់រហ័សទាន់សម័យនិយម ។

នៅតាមអគារសិក្សា យុវជនជាសិក្ខាកាម ត្រូវតែព្យាយាមរៀនសូត្រសព្វសាស្ត្រវិជ្ជាតាមដោយក្រិត្យក្រម ដើម្បីបណ្តុះនិស្ស័យវាសនារបស់ខ្លួន ឲ្យទៅជាអ្នកចេះដឹងឈ្លាសវៃ ឬជាអ្នកប្រាជ្ញបណ្ឌិតយ៉ាងចំណាន(១)ក្នុងពេលអនាគត ។

នៅក្នុងគ្រាអាសន្ន ដែលមានខ្មាំងសត្រូវចូលលុកលុយ

(១) ត្រូវថា ជំនាញ វិញ ត្រឹមត្រូវជាង ។

ប្រទេសជាតិ យុវជនទាំងអស់ត្រូវតែធ្វើពលីកម្មបេញគយុទ្ធពុះពារយ៉ាងអង់អាចជាមួយបច្ចាមិត្ត លុះត្រាតែជណ្តើមបានជោគជ័យជាអវសាន ។

យុវជនខ្មែរមិនត្រូវបណ្តែតបណ្តោយ ធ្វើឲ្យជីវិតមានតម្លៃរបស់ខ្លួន ដែលប្រៀបបានទៅបុប្ផាកំពុងរីកស្គុសស្គាយផ្សព្វផ្សាយគន្ធពិដោរនោះ ឲ្យស្រពាប់ស្រពោនទៅវិញបានឡើយ ។

ដោយសារកម្លាំង(២) រឹងប៉ឹងយ៉ាងប្រត្យក្សនៃយុវជននេះប្រទេសកម្ពុជានឹងបានទទួលអារ្យធម៌ ព្រមទាំងវឌ្ឍនធម៌បិតថេរចីរកាលយូរអង្វែង ដូចមហាប្រទេសសុីវិល័យនានាក្នុងសាកលលោក ។

## សំនួរ

១– ចូរពន្យល់ពាក្យ សតិសម្បជញ្ញៈ, សមត្ថភាព, ភាតព្វកិច្ច, ពលីកម្ម, ប្រត្យក្ស ។

---

(២) សុំអាននិទាន = ( introduction សម្រាប់បោះពុម្ពគ្រាទី ៥ ឆ្នាំ ១៩៦៨ របស់សម្តេចព្រះសង្ឃរាជ ទំព័រ (ង) ក្នុងវបនានុក្រមខ្មែរភាគ ១) ។

**២- ចូររកសទិសសព្ទ** *នៃពាក្យ "ការ" ។*

**៣- ចូរធ្វើសម្ពន្ធពាក្យ** *ដែលមាននៅក្នុងប្រយោគ „អ្នកសិក្សាការ ត្រូវតែព្យាយាមរៀនសូត្រសព្វសាស្ត្រវិជ្ជា" ។*

មធ្យមសិក្សាប័ត្រ

លើកទី ១ ថ្ងៃ ៦ . ៣ . ៦១

## កំណត់ចំណាំ

១- អក្ខរាវិរុទ្ធ :-

– **កម្លាំង** *(ត្រូវសរសេរតម្រួត ព្រោះមកពី* ខ្លាំង *។ ពីមុនអាចសរសេរជា* កំលាំង *ឬ* កំឡាំង *ដូច្នេះបាន) ។*

(សូមអាន វ. ន. ខ. ភាគ ១ ថ្មី ទំព័រ ២៣)។

– **បម្រើ** *(ត្រូវសរសេរតម្រួត ព្រោះមកពី* ប្រើ *ពីមុនអាចសរសេរ* បំរើ *។* (វ. ន. ខ. ភាគ ១ ថ្មី ទំព័រ ៥៥៥) ។

– រលឹក (អាចសរសេរ រឭក បាន) ។

– អារម្មណ៍ (កុំច្រឡំនឹង អារម្ភកថា, បារម្ភ) ។

– ឧត្តុង្គឧត្តម (អាចសរសេរ ឧដុង្គឧត្ដម បាន) ។

– សន្តាន-សន្តោស (សរសេរប្រកបនឹង ន្ត មិនមែននឹង ណ្ត ទេ) ។

– បរិសុទ្ធ (គុ.) ខុសគ្នានឹង បរិសុទ្ធិ (ជានាម) ។

– ហ្មត់ហ្មង (អាចសរសេរ ម៉ត់ម៉ង បាន ។

– ស្និទ្ធ (សរសេរ ស្និ នឹង ទ្ធ ) ។

– មិត្ត (អាចសរសេរ មិត្រ បាន) ។

– ភក្តិ (អាចសរសេរ ភ័ក្ដិ បាន) ។

– ប្រទូស្ត (អាចសរសេរ ប្រទូស បាន) ។

– ស្ម័គ្រស្មាគម (សរសេរ ស្ម័ នឹង គ្រ, ស្មា-គ នឹង ម ) ។

– ពៃរ៍ (សរសេរ ពៃ នឹង រ៍ ) ។

- **ចំពូក** (អាចសរសេរ បំពុក បាន) ។
- **អាសន្ន** (សរសេរ ស និង ន្ន ) ។
- **តម្លៃ** (មិនសរសេរ តំលៃ ឬ ដំឡៃ ដូច្នេះទេ ។ មកពីពាក្យ ថ្លៃ ត្រូវសរសេរតម្រួត) ។
- **ចម្រើន** (ត្រូវសរសេរតម្រួត ព្រោះមកពីពាក្យ ច្រើន ។ ពីមុនសរសេរ ចំរើន បាន) ។
- **ចីរកាល** (គេអានថា ចៀរកាល ។ គេសរសេរ ចឹរ កាល) ។
- **ឋិតថេរ** (ឋិត សរសេរនឹង ឋ ។ ថេរ សរសេរ នឹង ថ) ។
- **សាកលលោក**(អាចសរសេរ សកលលោកបាន)។

២- **សទិសសព្ទ** នៃពាក្យ :

១- ប្រមាថ :

-- **ប្រមាថ** ជានាម ប្រែថា ការបៀតបៀនគេ, ការ

មើលងាយគេ ។

- **ប្រមាទ** ជានាម ប្រែថា ការភ្លេចស្មារតី, ធ្វេសស្មារតី ។

- ជាកិ. ប្រែថា ភ្លេច, ធ្វេស, ប្រហែស (ជនណាប្រមាទ ជននោះទុកដូចជាបុគ្គលស្លាប់) ។

២- ការ :

- **ការ** ជានាម ប្រែថា អំពើដែលត្រូវធ្វើ (ធ្វើការ, មានការ) ។

- **ការ** ជានាម គឺពាក្យសំរាប់ប្រើដាក់ខាងដើមពាក្យដែលជាកិរិយាសព្ទផ្សេងៗ (ការសំពះ) ។

- **ការ** ជាកិ. គឺមូរសរសៃសូត្រ (ការសូត្រ) ។

- **ការ** ជាកិ. ប្រែថា បិទបាំង, រាំងរា, ឃាត់ខាំង (ការមិនឲ្យសត្រូវចូលមក) ។

- **ការ** ជាកិ. គឺរៀបចំផ្សំផ្គុំបុរសនិងស្ត្រី ឲ្យបានគ្នា